

# Resilience

## celebrating the lives of Cambodian peace builders



# Resilience

## celebrating the lives of Cambodian peace builders

Researched and prepared
by Seng Sakara

Supported by
The Centre for Peace and Conflict Studies, Cambodia
The Haas Center for Public Service of Stanford University

# មាតិកា


អារម្ភកថា ............ ៣
ជា វណ្ណាត ............ ៤
ជាង សុខា ............ ៦
ហួត ថាវរី ............ ១០
ហ៊ុយ រំដួល ............ ១៤
ធីតា ឃិះ ............ ១៦
មាស សូកែវ ............ ១៨
ណែប ស៊ីនថៃ ............ ២០
នៅ កាស៊ី ............ ២២
សេក សារុំ ............ ២៤
សុង កុសល ............ ២៨
ទូច វ៉ារីន ............ ៣០
យ៉េង វីរះ ............ ៣២
ឡុង ខែត ............ ៣៤


# Contents


Introduction ............ 3
*Chea Vannath* ............ 4
*Cheang Sokha* ............ 6
*Huot Thavory* ............ 10
*Huy Romduol* ............ 14
*Khus Thida* ............ 16
*Meas Sokeo* ............ 18
*Neb Sinthay* ............ 20
*Neou Kassie* ............ 22
*Sek Sarom* ............ 24
*Song Kosal* ............ 28
*Touch Varine* ............ 30
*Yeng Virak* ............ 32
*Long Khet* ............ 34

# អារម្ភកថា

កម្រងរបាយការណ៍ទាំងអស់ក្នុងសៀវភៅនេះជារឿងផ្ទាល់របស់មនុស្ស ១៣ នាក់  ដែលជាឧទាហរណ៍បញ្ជាក់អំពីបុគ្គលមួយចំនួនដែលចេះកែឆ្នៃបទពិសោធន៍ពីការទាស់ទែងគ្នាឲ្យក្លាយទៅជាចំណង់សំរាប់កសាងសន្តិភាពឲ្យបានជានិរន្ត។ នេះជាសៀវភៅដែលចងក្រងពីសំភាសដែលនាងខ្ញុំបានធ្វើនៅពាក់កណ្តាលឆ្នាំ ២០១១ នៅប្រទេសកម្ពុជា បន្ទាប់ពីបានទទួលការអនុញ្ញាតិពីមហាវិទ្យាល័យនាងខ្ញុំ នៅសហរដ្ឋអាមេរិក។ ខ្ញុំមានឱកាសដ៏ល្អពិសេសដោយបានស្តាប់អំពីជីវិតនឹងដំបូន្មានរបស់ខ្មែរអ្នកកសាងសន្តិភាពទាំង ១៣ នាក់ ចំណង់ដ៏ខ្លាំងក្លារបស់គាត់នឹងការសុខចិត្តចែករំលែកប្រវត្តិរូបមនោសញ្ចេតនានឹងមហិច្ឆិតាជាមួយខ្ញុំ ដែលខ្ញុំមិនបានស្មានទាល់តែសោះ។ ខ្ញុំមើលឃើញទស្សនៈនៅក្នុងដំបូន្មានរបស់គាត់ទាំងអស់ដែលខ្ញុំខំចំលងដោយផ្ចិតផ្ចង់នូវប្រវត្តិដែលគាត់បានបកស្រាយប្រាប់ខ្ញុំ។ អត្ថបទនេះជាបំណងរបស់ខ្ញុំក្នុងការជួយផ្សប់ផ្សាយឲ្យបានទៅដល់ខ្មែរទាំងអស់ ខ្មែរអាមេរិកាំងនឹងអ្នកទាំងអស់ដែលចាប់អារម្មណ៍ក្នុងរឿងនេះ អំពីមេរៀនអ្នកកសាងសន្តិភាពទាំងនេះបានបកស្រាយឲ្យខ្ញុំនឹងការយល់ដល់របស់ខ្ញុំពេលបានស្តាប់គាត់។ បើគាត់ទាំងអស់មិនបានចូលរួមនឹងគាំទ្រទេខ្ញុំមិនអាចរៀនសូត្រអំពីទំនាស់ដែលប្រទេសកម្ពុជាបានឈមមុខក្នុងឋានៈជាប្រទេសដែលកំពុងអភិវឌ្ឍ ហើយក៏ខ្ញុំមិនអាចយល់ដឹងឲ្យពិតប្រាកដអំពីប្រវត្តិរបស់គ្រួសារផ្ទាល់របស់ខ្ញុំដែរ។ បទពិសោធន៍នេះបានបង្ហាត់ខ្ញុំពីអ្វីដែលខ្ញុំមិនបានយល់ពីមុន ខ្ញុំសូមអរគុណចំពោះអ្នកចូលរួមទាំងអស់ចំពោះ The Haas Center នៃមហាវិទ្យាល័យ Stanford នឹង the Center for Peace and Conflict Sudies ព្រមទាំងគ្រួសារខ្ញុំដែលធ្វើឲ្យគំរោងការនេះសំរេចបានដោយជោគជ័យ។

សេង សាការ៉ា

# Introduction

This story collection is a book of thirteen passages that illustrate how some individuals have transformed their experiences with conflict into motivation to build sustainable peace. It is the culmination of several interviews I conducted in the summer of 2011 on an undergraduate fellowship in Cambodia.  I had the wonderful opportunity to listen to the lives and advice of Cambodian peacebuilders, and their enthusiasm and willingness to share their history, feelings, and aspirations with me was more than I could have ever hoped for.  I found such insight in their advice that I struggled to convey concisely the beautiful and moving tales they gave me.  These writings are my attempt to share with others - Khmer, Khmer-Americans, and others interested - the lessons these peacebuilders shared with me and the realizations I had while listening.  Without their participation and support, I would not have learned about the conflicts facing Cambodia as a developing country nor gained a better understanding of my own family's history.  This experience has been a transformation - thank you very much to the participants, the Haas Center for Public Service of Stanford University, the Centre for Peace and Conflict Studies, and my family for making it possible.

Seng Sakara

# ជា វណ្ណាត



លោកស្រីវណ្ណាត បានសារភាពថា ទាំងសកម្មភាពលោកស្រីខាងផ្នែកលទ្ធិប្រជាធិបតេយ្យ ទាំងជំហ៊ារដឹកនាំលោកស្រីក្នុងសង្គមពលរដ្ឋខ្មែរគឺមិនមានជាចំណែកនៃផែនការណាមួយទេ។ រស់នៅក្នុងគ្រួសារលោកស្រីដែលមានជំនឿស៊ប់ ទៅក្នុងព្រះពុទ្ធសាសនា លោកស្រីត្រូវបានរៀនតាំងពីពេលលោកស្រីនៅតូច ថាការផ្លាស់ប្តូរគឺជាភាពតែមួយគត់ដែលពិតប្រាកដ។ លោកស្រី មិនដែលរំពឹងគិតដល់អនាគតលោកស្រីឡើយ ហើយនិយាយដោយងាយស្រួលថា *"ការរំពឹងគិតឬការគ្រោងទុកជាមុនមិនមែនជាលក្ខណះរបស់ខ្ញុំទេ...ដល់ថ្ងៃណាសឹមថ្ងៃនឹង"*។

លោកស្រីវណ្ណាត បានចំណាយពេលជិតម្ភៃឆ្នាំក្នុងការជួយកសាងប្រទេសកម្ពុជា។ ក្នុងឋានៈជាប្រធាននៃគណៈកម្មាធិការដើម្បីបោះឆ្នោតដោយសេរីនឹងយុត្តិធម៌នៅប្រទេសកម្ពុជា ទសវត្សរ៍១៩៩០ លោកស្រីបានតាមដានដំណើរការនៃការបោះឆ្នោតដើម្បី កែលំអរដំណើរការនេះឲ្យបានកាន់តែត្រឹមត្រូវឡើង។ ក្នុងឋានៈជាប្រធាននៃមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមពីឆ្នាំ១៩៩៦ ដល់ ឆ្នាំ២០០៦ លោកស្រី បានធ្វើឲ្យរីកចំរើនក្នុងការទទួលខុសត្រូវ នឹងការចូលរួមរបស់ពលរដ្ឋក្នុងសកម្មភាពសង្គមនានា។ នៅលើឆាកអន្តរជាតិលោកស្រីជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីទាំង ១000 នាក់ ដែលត្រូវបានជ្រើសរើសជាអ្នកអាចទទួលរង្វាន់ណូបែលឆ្នាំ ២០០៥។

ថ្វីបើជ័យជំនះបានមកពីការយកចិត្តទុកដាក់ នឹងការប៉ិនប្រសប់របស់លោកស្រីក៏ដោយ លោកស្រីវណ្ណាត នៅតែនឹកទៅដល់ការប្រឹងប្រែងតស៊ូរបស់លោកស្រី ដើម្បីឲ្យក្លាយទៅជាសកម្មជនដែលបានត្រូវគេទទួលស្គាល់ដល់សព្វថ្ងៃនេះ។

# Chea Vannath

For Vannath, neither her extensive activism for democracy nor her leadership in Cambodian civil society was part of any plan. Growing up in a devout Buddhist family, she was taught early on that change is the only certainty. She did not dream of her future and says simply, *"dreaming and planning is not my type…I choose day by day."*

Vannath has spent almost 20 years helping to reconstruct and rehabilitate her war-torn country. As president of the Coalition for Free and Fair Elections in the early 90s, she monitored election processes in order to improve transparency. Then, as president of Cambodian Social Development from 1996-2006, she helped establish the first series of public forum debates on national issues, as well as the first national survey on corruption and the first national curriculum on transparency and accountability. As a testament to her dedication, she was one of 1000 women nominated for the Nobel Peace Prize in 2005.

Although her accomplishments speak to her focus and ability, Vannath remembers her struggle to become the activist she is known as today. She recalls, *"When I arrived in the [refugee] camps, they [fellow refugees] looked at me like I was their savior."* She explains that because she was one of few surviving members of the educated class, they expected her to be a leader. But being a leader was not her disposition. In her time, Cambodian women were not vocal. They were not involved in the greater community, and neither was she. When asked what made her decide to become an activist, she says, *"my awakening was seeing Khmer wander from the tombs like living ghosts…"* Her experiences with suffering were her motivation. *"Although it went against my culture, I decided to be involved."*

លោកស្រី នឹកឡើងវិញ "ពេលខ្ញុំបានមកដល់ជំរុំភៀសខ្លួនគេ(ជនភៀសខ្លួន)មើលមកខ្ញុំថាជាអ្នកមកសង្គ្រោះគេទាំងអស់គ្នា។" លោកស្រីពន្យល់ថា ពីព្រោះលោកស្រីជាជនម្នាក់ក្នុងចំណោមអ្នកនៅរស់សេសសល់ពីស្លាប់ដ៏តិចតួចដែលឋិតនៅក្នុងសង្គមអ្នកចេះដឹង។ គេទាំងនោះ សង្ឃឹមថាលោកស្រីត្រូវធ្វើជាអ្នកដឹកនាំ។ ប៉ុន្តែជាអ្នកដឹកនាំ មិនមែនជានិន្នាការលោកស្រីទេ។ នៅពេលនោះ ស្ត្រីខ្មែរមិនមែនជាអ្នកបញ្ចេញមតិឡើយ ស្ត្រីខ្មែរមិនទាក់ទងនឹងសង្គមធំៗ ហើយលោកស្រីក៏ដូចស្ត្រីឯទៀតៗដែរ។ ពេលសួរថាហេតុអ្វីលោកស្រីសំរេចចិត្តធ្វើជាសកម្មជន លោកស្រីឆ្លើយថា "ការភ្ញាក់រលឹករបស់ខ្ញុំគឺដោយការឃើញខ្មែរហាក់ដូចខ្មោចរស់ដើរវង្វេងវង្វេរវាយចេញពីផ្ទះ"។ បទពិសោធន៍លោកស្រីជាមួយការវេទនា បានជំរុញចិត្តលោកស្រីឲ្យធ្វើ។ "ទោះដឹងថា ការធ្វើនេះ មិនទំនងនឹងវប្បធម៌ខ្មែរក្តី ខ្ញុំនៅតែសំរេចចិត្តជួយបំរើសង្គម"។

ចំពោះអ្នកជំនាន់ក្រោយ លោកស្រីវណ្ណាត សូមរំលឹកអ្នកទាំងអស់គ្នាថា ជីវិតជាការតស៊ូដើម្បីឲ្យមានលំនឹងតុល្យភាព។ មនុស្សម្នាក់ៗត្រូវតស៊ូដើម្បីរក្សាលំនឹងរវាងការលូតលាស់រាងកាយនឹងស្មារតី, រវាងការលូតលាស់នៅក្នុងរង្វង់គ្រួសារនឹងរង្វង់ការងារ។ "កម្ពុជាត្រូវធ្វើការថ្លឹងថ្លែងរវាងការរីកចំរើនជាតិនឹងសេចក្តីថ្លៃថ្នូរនៃមនុស្ស"។ លោកស្រីពន្យល់ "ខ្ញុំមិនជាល្ងង់រហូតទៅគិតថាខ្ញុំអាចកែឆ្នៃប្រទេសបានទេ ប៉ុន្តែខ្ញុំបន្តការប្រយុទ្ធតស៊ូ"។ បើនៅតែមានការតស៊ូ លោកស្រីជឿថាគឺនឹង មានសេរីភាពក្នុងការជ្រើសរើស។ ចំពោះរូបលោកស្រីផ្ទាល់ លោកស្រីវណ្ណាត បានពុះពារដើម្បីឲ្យបានជាការប្រាកដថា យុវជនជាន់ក្រោយដែលនឹងដឹកនាំប្រទេសជាតិនឹងមានសេរីភាពក្នុងការជ្រើសរើសដើម្បីស្ថាបនាអនាគតដែលមានលំនឹងតុល្យភាពមាំមួន។



For the future generation, Vannath reminds them that life is a struggle for balance. Each person balances between physical and mental growth, family and work. *"Cambodia must balance between national growth and the dignity of the people."* She explains, *"I am not so naïve as to think I can change the country, but I continue fighting for the struggle."* As long as the struggle exists, she believes the freedom to make change is possible. In her dedication, Vannath strives to ensure that young leaders have the freedom of choice to build a balanced future.



# ជាង សុខា

សុខាមានការចាប់អារម្មណ៍ និងបើកចិត្តយ៉ាងទូលាយក្នុងការចែករំលែកពីបទពិសោធន៍ និងជីវិតតស៊ូរបស់គាត់ចំពោះខ្ញុំ។ សម្ដីរបស់គាត់ពោរពេញទៅដោយខ្លឹមសារដែលបង្ហាញពីការចេះដឹងដោយមានការដកស្រង់អត្ថបទចេញពីអ្នកនិពន្ធជាច្រើនដែលសុខាបានប្រមូលទុកក្នុងរយៈពេលជាង២០ឆ្នាំកន្លងមកនេះ។ គាត់និយាយថា "សម្រាប់គាត់ មិនមានគ្រូបង្រៀនជាក់លាក់ណាម្នាក់ដែលបានណែនាំ ឬបង្រៀនថាតើគួរធ្វើដូចម្ដេចដើម្បីដឹកនាំជីវិតរបស់ខ្លួនឯងឲ្យបានជោគជ័យ ឬបង្ហាញពីអ្វីជាតម្លៃនៃជីវិតរបស់ខ្លួននោះឡើយ" ទោះបីជាយ៉ាងណាក៏ដោយ គ្រូទាំងអស់ និងឪពុកម្ដាយរបស់គាត់បានជួយរៀបចំខ្លួនគាត់ឲ្យមានមូលដ្ឋានគ្រឹះក្នុងការរៀបចំជីវិត។ លើសពីនេះទៀត អ្វីដែលមានឥទ្ធិពលសំខាន់មកលើគាត់គឺគំនិតអប់រំដែលដកស្រង់ចេញពីសៀវភៅរបស់អ្នកនយោបាយ និងបញ្ញវន្តនានាបានក្លាយទៅជាអ្នកដឹកនាំ និងជាមគ្គុទេសត្រួសត្រាយផ្លូវដ៏ប្រសើរសម្រាប់អនាគតរបស់គាត់។ ក្នុងវ័យកុមារភាព សុខាចូលចិត្តអានសៀវភៅប្រលោមលោកជាច្រើនដែលនិយាយអំពីតួឯកក្លាហាន ហ៊ានធ្វើការប្រយុទ្ធដើម្បីប្រជាជន ហើយតួឯកនៅក្នុងប្រលោមលោកទាំងនោះបានក្លាយទៅជាជនគំរូសម្រាប់គាត់។

សុខាបានរំលឹកឡើងវិញទាំងទឹកមុខក្រៀមក្រំថា គាត់មិនធ្លាប់ស្គាល់ភាពរីករាយក្នុងភាពជាកុមារដូចក្មេងៗបច្ចុប្បន្ននេះឡើយក្នុងកាលៈទេសៈដែលស្រុកទេសជួបប្រទះវិបត្តិសង្គ្រាមផ្ទៃក្នុង និងការកាប់សម្លាប់ជាតិសាសន៍ឯងនៃរបបខ្មែរក្រហមដែលយកចុងកាណុងកាំភ្លើង និងហិង្សាជាដំណោះស្រាយ។ គាត់តស៊ូដើម្បីរស់រហូតដល់អាយុ ១០ឆ្នាំ ទើបរបបដ៏ខ្មៅងងឹតនេះត្រូវបានដួលរលំ។ ពេលសួររំលឹកពីរបបនេះ គាត់ថា គាត់គ្មានកំហឹង និងចងគំនុំចំពោះអ្នកដើរតាមរបបខ្មែរក្រហមឡើយ

# Cheang Sokha

Sokha was eager to share his journal. In it was an assortment of quotes that he has been collecting for over 20 years. He said that he doesn't recall specific teachers who showed him how to be a leader or what to value in life, but that words from various books, politicians, and scholars are his guide. When he was younger, he loved reading novels about protagonists who were "brave" and "fought for the people." They became his role models.

At ten years old, Sokha survived the Khmer Rouge years. He grew up during the civil war, in an environment where guns were the solution and the roads were dangerous. When asked if today he feels anger or bitterness towards the KR, he said he does not.

*"Who wanted to live in the jungle hungry, mosquito-bitten, and with no shelter from the rain and wind? No one. If the man quit, he would be accused of betrayal then killed. If he ran away, the army would catch and kill him. They were only motivated by their stomachs. I am not angry with the soldiers. They were victims, too."*

In 1989 at the age of 18, Sokha ventured from his home province of Takeo to get a higher education in Phnom Penh. He explained that the most difficult part was arriving in Phnom Penh at midnight, a poor farmer's son who knew nobody and had no place to sleep. Five years later, he left the capital with a bachelor's degree in Psychology and Pedagogy from the Royal University of Phnom Penh and began his career as a teacher.



ដោយយល់ថាពួកគេក៏ជាជនរងគ្រោះដូចជាគាត់ដែរ ប៉ុន្តែអ្នកដឹកនាំរបបនេះត្រូវតែទទួលការកាត់ទោសតាមច្បាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ សុខាពន្យល់ទៀតថា នៅឆ្នាំ១៩៩៤ គាត់បានជួបជាមួយទាហានខ្មែរក្រហមដែលរស់នៅក្នុងព្រៃនៃខេត្តស្ទឹងត្រែង។ ស្ថានភាពនេះបានធ្វើឲ្យគាត់គិតថា មិនមាននរណាម្នាក់ដែលចង់រស់នៅក្នុងព្រៃឲ្យមូសខាំ ដោយគ្មានជំរក ត្រូវភ្លៀង ត្រូវខ្យល់ និងមិនមានអាហារគ្រប់គ្រាន់នោះឡើយ។ ផ្ទុយទៅវិញបើអ្នកនោះមិនព្រមធ្វើតាមបញ្ជាទេ នឹងត្រូវគេចោទថាជាជនក្បត់ដែលត្រូវតែយកទៅកំទេច ហើយបើហ៊ានលួចរត់ចេញ ពួកទាហ៊ាននឹងតាមចាប់ខ្លួនរួចសម្លាប់ចោលដូចគ្នា។ ដូចនេះពួកគេគ្មានជំរើសអ្វីក្រៅពីស្តាប់បញ្ជា ដើម្បីដោះស្រាយបញ្ហាក្រពះ និងអាយុជីវិតរបស់គេរៀងៗខ្លួននោះទេ។ នេះមិនមែនមានន័យថា សុខាគាំទ្រចំពោះមេដឹកនាំខ្មែរក្រហមដែលបានកាប់សម្លាប់មនុស្សយ៉ាងរង្គាល និងដឹកនាំប្រទេសឆ្ពោះទៅរកវិនាសកម្មនោះឡើយ។

Sokha is currently the Executive Director of the Youth Resource Development Program, a well-established, local NGO that offers free courses to university students to develop critical thinking skills and social responsibility. He strongly believes that receiving an education means receiving not a certificate, but rather the tools and ability to respond to changing situations. Today Cambodia is undergoing change unlike any in its history. Sokha is determined to arm the next generation with the intelligence and conscience to create a peaceful future.

*"There are no limitations to the mind except for those we acknowledge."* – Napoleon Hill



ក្នុងឆ្នាំ១៩៨៩ ពេលអាយុបាន១៨ឆ្នាំ សុខាបានផ្សងព្រេងដោយចាកចេញពីស្រុកកំណើតនៅខេត្តតាកែវទៅបន្តការសិក្សានៅទីក្រុងភ្នំពេញ។ គាត់បានរៀបរាប់ថា រឿងដែលគាត់នៅតែមិនអាចបំភ្លេចបាននោះ គឺជីវិតសិក្សានៅទីក្រុង។ សុខាបានចាកចេញពីស្រុកកំណើតមកដល់ភ្នំពេញដំបូងទាំងកណ្ដាលអធ្រាត្រតាមរយៈរថភ្លើង ហើយថែមទាំងមិនស្គាល់ទីក្រុង និងមិនដឹងថាត្រូវស្នាក់នៅកន្លែងណាទៀត។ គាត់រស់នៅក្នុងជីវិតដែលពោរពេញទៅដោយការតស៊ូព្យាយាមអស់រយៈពេលបួនឆ្នាំ ដើម្បីបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ។ ៥ ឆ្នាំក្រោយមក សុខាបានចាកចេញពីរាជធានីបន្ទាប់ពីបានទទួលបរិញ្ញាបត្រផ្នែកចិត្តវិទ្យាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ហើយចាប់ផ្ដើមជីវិតជាគ្រូបង្រៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង។

សព្វថ្ងៃនេះ សុខាជានាយកប្រតិបត្តិនៃអង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន ដែលជាអង្គការក្នុងស្រុកមួយធ្វើការផ្ដោតសំខាន់ទៅលើយុវជននៅតាមមហាវិទ្យាល័យ និងសាកលវិទ្យាល័យនានាដោយបណ្ដុះបណ្ដាលពួកគេទៅលើជំនាញគិតពិចារណាស៊ីជម្រៅ និងមនសិការសង្គម។ សុខា មានជំនឿយ៉ាងមុតមាំថា មានតែការអប់រំដែលប្រកបដោយគុណភាពប៉ុណ្ណោះដែលអាចជួយដឹកនាំខ្លួនឯង និងសង្គមឲ្យរីកចម្រើនបាន។ ក្នុងន័យនេះ គាត់យល់ឃើញថា ការអប់រំដែលមានគុណភាពមិនមែនសំខាន់តែក្នុងការទទួលបាននូវសញ្ញាបត្រនោះទេ ប៉ុន្តែសំខាន់គឺយកអ្វីដែលបានសិក្សាមកអនុវត្តជាសកម្មភាព ដើម្បីធ្វើឲ្យមានការផ្លាស់ប្ដូរជាវិជ្ជមាននៅស្ថានភាពនៃការរស់នៅផ្ទាល់ខ្លួន និងសង្គម។

បច្ចុប្បន្ននេះ កម្ពុជាកំពុងតែបន្តវិវឌ្ឍនទៅមុខ ហើយយុវជនត្រូវបានគេមើលឃើញថាជាកម្លាំងចលករ ឬជាភ្នាក់ងារដែលនាំឲ្យមានការផ្លាស់ប្ដូរសង្គម។ សុខា ប្ដេជ្ញាថានឹងបន្តបណ្ដុះបណ្ដាលយុវជនឲ្យមានគុណភាព និងលើកទឹកចិត្តដល់ពួកគេឲ្យពង្រឹងមនសិការសង្គម និងមានទំនួលខុសត្រូវចំពោះវាសនាអនាគតរបស់ខ្លួន គ្រួសារនិងសង្គមទាំងមូល តាមរយៈការការពង្រឹងនូវជំនាញនៃការគិតពិចារណាស៊ីជម្រៅ ដើម្បីឲ្យពួកគេអាចធ្វើការវិភាគពីបញ្ហាសង្គម និងជំរុញឲ្យពួកគេបានចូលរួមយ៉ាងសកម្មក្នុងការកសាងវប្បធម៌សន្តិភាព យុត្តិធម៌ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។

*"ប្រាជ្ញារបស់មនុស្សពុំមានដែនកំណត់ទេ វៀរលែងតែយើងទទួលស្គាល់ថាមាន"*


1
10
9
8
7
6
5
4

# ហួត ថាវរី



មកដល់ឆ្នាំ១៩៧០ ថាវរីលែងនឹកឃើញថា តើនាងរត់ចូលលេណដ្ឋានប៉ុន្មានដង ដើម្បីគេចវៀសពីគ្រាប់បែកអាមេរិកាំង។ ពេលនាងមានអាយុ ១៥ ឆ្នាំ ការធ្វើបដិវត្តន៍របស់ខ្មែរក្រហម បានរាលឆ្លងមកដល់ភូមិរបស់នាងក្នុងខេត្តកំពង់ធំ។ នាងនិងយុវជនឯទៀតនៅក្នុងភូមិត្រូវបានគេជ្រើសរើសឲ្យទៅជួយបង្កើនចលនាខ្មែរក្រហម។ "ពេលយប់ខ្ញុំធ្វើដំណើរ ទៅនិយាយតាមភូមិជិតខាង។ ខ្ញុំនិយាយអំពីអំពើអយុត្តិធម៌ពីការទំលាក់គ្រាប់បែករបស់អាមេរិកាំង ការជិះជាន់ដោយអ្នកមូលធន ប្រមូលយកប្រាក់ពីកសិករយើង ដែលជាអ្នកធ្វើការ និងពីការធ្វើដូម្តេចដើម្បីងើបឈរឡើងប្រឆាំងនឹងលន់ណុល និងពួកមូលធននិយម"។ ថាវរីលែងចាប់អារម្មណ៍ជាមួយចលនាខ្មែរក្រហម ពេលខ្មែរក្រហមចាប់ផ្តើមកែនទាហានក្មេងៗឲ្យទៅច្បាំងនៅសមរភូមិមុខ ហើយប្អូនប្រុសនាងដែលជាទាហានខ្មែរក្រហមដែរបានត្រូវស្លាប់ដោយរោគគ្រុនចាញ់នៅអាយុ ១៦ឆ្នាំ។

នាងរស់នៅក្នុងទីក្រុងភ្នំពេញបានបួនឆ្នាំមុនខ្មែរក្រហមលុកលុយរដ្ឋធានី។ ថាវរីត្រូវគេជំលៀសចេញជាមួយប្រជាជនឯទៀត ហើយត្រូវគេជំរុញឲ្យទៅធ្វើការជាមួយ

# *Huot Thavory*

By 1970, Thavory could not remember how many times she had taken refuge in trenches to escape the American bombs. She turned 15 that year and the Khmer Rouge revolution had just reached her village in Kampong Thom. They recruited her and other village youth to help further the movement: *"At night I traveled to give speeches at surrounding villages. I spoke about the injustice of the carpet bombing, about the capitalists taking all the money while the farmers did the work, and how we should rise against Lol Nol and the capitalist suppressors."* Thavory became disenchanted with the movement when the KR mobilization began - when child soldiers were sent to the front lines of the fighting and her 16-year-old younger brother, a KR soldier, died of malaria.

She had lived in Phnom Penh for only one year before the KR overran the capitol. Thavory was evacuated with the rest of the population and sent to work in the mobile youth units digging irrigation dams: *"Working under the hot sun led to skin diseases. Sometimes I thought I would rather die than suffer through the [incessant] itching."* When the country came under Vietnamese control, she explained how violence echoed throughout communities: *"Some students carried guns to schools to show off their family status. Men would fight over traffic accidents. No one felt safe."*

Her experiences led her to join the Working Group for Weapons Reduction in 2001. With them, she helped write a national curriculum on peace and disarmament and travelled across the country to train teachers on weapons law and methods to teach young people about the dangers of small arms. This work also led





កងចល័តជីកប្រឡាយទឹក។ ធ្វើការក្រោមកំដៅព្រះអាទិត្យ និងកង្វះអនាម័យធ្វើឲ្យថាវរីកើតជម្ងឺសើស្បែក។ ពេលខ្លះខ្ញុំនឹកថាសុខចិត្តស្លាប់ជាជាងទទួលទុក្ខវេទនា ដោយមានជម្ងឺរមាស់(មិនឈប់)។ នាងពន្យល់ពីអំពើឃោរឃៅដែលកើតឡើងក្នុងសហគមន៍។ ក្រោយរបបខ្មែរក្រហមដួលរលំទៅ។

"ដូចជានិស្សិតខ្លះយកកាំភ្លើងទៅសាលា ដើម្បីសំញៀងឲ្យគេដឹងពីឋានៈគ្រួសារគេ។ មនុស្សឈ្លោះគ្នាពីព្រោះគ្រោះថ្នាក់ចរាចរបន្តិចបន្តួច។ យើងមានអារម្មណ៍ថា ស្រុកទេសសាន្តត្រាណមែន ប៉ុន្តែគ្មានសុវត្ថិភាពនៅឡើយ"។

បទពិសោធន៍ទាំងនេះ នាំនាងឲ្យទៅចូលជាបុគ្គលិកនៃក្រុមការងារដើម្បីកាត់បន្ថយអាវុធ (the Working Group for Weapon Reduction, WGWR) ឆ្នាំ ២០០១។ ជាមួយក្រុមការងារនេះនាងបានជួយសរសេរកម្មវិធីសិក្សាស្តីពីការអប់រំសន្តិភាព ការដកហូតអាវុធ ហើយបានធ្វើដំណើរទូទាំងប្រទេសទៅបង្ហាត់គ្រូបង្រៀនអំពីកិច្ចការដកហូតអាវុធ ការអប់រំសន្តិភាព និងអំពីគ្រោះថ្នាក់នៃអាវុធតូច។ ការងារនេះនាំនាងរហូតទៅដល់ប្រទេសឯទៀតៗដូចជា ប៉េរូ អាល់បានី និង ប្រទេសអាឡឺម៉ង់ ដើម្បីចែករំលែកបទពិសោធន៍របស់នាងអំពីការផ្លាស់ប្តូរពីអំឡុងពេលសង្គ្រាមទៅការបញ្ចប់សង្គ្រាម។

បច្ចុប្បន្ននេះ ថាវរីជានាយកប្រតិបត្តិនៃខ្មែរអហិង្សាដែលជាអង្គការក្រៅរដ្ឋាភិបាល ធ្វើការពង្រីងដំណោះស្រាយទំនាស់តាមវិធីសាស្ត្រអហិង្សា ។ តាមរយៈការអប់រំដោយមានការពិភាក្សាគ្នា ស្តីពីហិង្សាក្នុងគ្រួសាររហូតទៅដល់ទំនាស់កម្មសិទ្ធិដី ថាវរីសង្ឃឹមថានឹងជួយបន្ធូរចំណង់ទៅរកការឃោរឃៅដែលនាងបានជួបប្រទះពីមុន។ បើឱកាសហុចឲ្យដើម្បីផ្តល់ឱវាទចំពោះក្មេងជាន់ក្រោយ ថាវរីឆ្លើយថា "ជីវិតជាខួបវិលចុះវិលឡើង បើថ្ងៃនេះពិបាក ថ្ងៃស្អែកនឹងស្រណុក បើថ្ងៃនេះស្រណុកថ្ងៃស្អែកនឹងពិបាក។ អ្នកត្រូវតែចេះអត់ធ្មត់ និងព្យាយាមពីព្រោះអ្វីៗទាំងអស់មិនទៀងទាត់។ អ្វីៗទាំងអស់ពិតជាអាចផ្លាស់ប្តូរ"។



her to countries such as Peru, Albania, and Germany to share her experiences with her transition from war to post-war.

Today, Thavory is the executive director of Khmer Ahimsa, a non-governmental organization advocating non-violent resolutions to local conflicts. Through conducting workshops on issues ranging from domestic violence to land advocacy, Thavory hopes this type of education might undo the tendencies towards violence that she has long witnessed. If given the opportunity to advise the young generation, Thavory says, *"Life is a cycle. If today is hard, tomorrow will be easy, and if today is easy, tomorrow will be hard.  You must be patient because everything impermanent. Things can always change."*



# ហ៊ុយ រំដួល

ក្នុងរយៈពេលដប់ឆ្នាំ រំដួលបានធ្វើការដើម្បីពង្រឹងការទាក់ទងរវាងមន្ត្រីក្នុងរដ្ឋា-ភិបាល ប្រជាជន អ្នកដឹកនាំសហគមន៍ទាំងអស់នឹងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល។ តាមរយៈការវិភាគពីករណីក្នុងស្រុក កម្មវិធីសិក្សារបស់រំដួល បានទាញយកហេតុផលនៃទំនាស់ទៅបង្កើតជាកម្មវិធីសំរាប់ដំណោះស្រាយនៃបញ្ហា នឹងសំរាប់ការជំនាញខាងការទាក់ទងគ្នា។ គាត់យកចិត្តទុកដាក់ក្នុងការជួយអ្នកចូលរួមឲ្យស្រាវជ្រាវដោយខ្លួនឯងពីរឿងការទុកចិត្តគ្នា នឹងការយោគយល់គ្នា។ រំដួលជាអ្នកចាស់ទុំ នឹងជាអ្នកដឹកនាំខាងការអប់រំចំពោះការធ្វើការដើម្បីសន្តិភាពដែលជាកម្មវិធីអភិវឌ្ឍន៍នៃសង្គមនៅក្រោមការគ្រប់គ្រងរបស់វិទ្យាស្ថានអភិវឌ្ឍន៍នឹងធនធានកម្ពុជា។ គាត់បានធ្វើការតស៊ូដើម្បីជោគជ័យនឹងដើម្បីបន្តកម្មវិធីនេះ ហើយពន្យល់ថា "កម្ពុជាត្រូវតែធ្វើឲ្យមានការទាក់ទងគ្នាពីគ្រប់ជាន់ថ្នាក់។ របៀបនេះហើយដែលយើងអាចពង្រឹងការជំនួយការតស៊ូនឹងកិច្ចការសន្តិភាព"។

ពេលសួរថា ហេតុអ្វីលោកស្រីបានចំណាយពេលដើម្បីកិច្ចការខាងអភិវឌ្ឍន៍សង្គម គាត់ឆ្លើយថា "ខ្ញុំត្រូវគេសំណូមពរឲ្យជួយប្រទេសជាតិ។ ខ្ញុំបានរៀនសូត្រខ្ពស់ជាងអ្នកឯទៀតដ៏ច្រើន។ ខ្ញុំធ្វើនេះពីព្រោះខ្ញុំស្រឡាញ់ប្រទេសជាតិខ្ញុំ"។

ក្នុងឋានៈជាស្ត្រីក្មេងម្នាក់ ក្នុងឆ្នាំ១៩៧២ រំដួលបានផ្លាស់ទៅនៅក្រុងភ្នំពេញ ដើម្បីបន្តការសិក្សា។ បន្ទាប់ពីបានចូលសិក្សាបានមួយឆ្នាំក្នុងសកលវិទ្យាល័យមកគាត់ឈប់បាន ទទួលលុយពីឪពុកម្តាយគាត់។ រដ្ឋធានីត្រូវបានកាត់ផ្តាច់ពីខេត្តបាត់ដំបងដោយសារផ្លូវជាតិលេខ៥ក្លាយទៅជាសមរភូមិមុខនៃសង្គ្រាមរវាងទាហ៊ានរដ្ឋាភិបាលនឹងខ្មែរក្រហម ការធ្វើដំណើរតាមផ្លូវមានគ្រោះថ្នាក់ជាខ្លាំង ហើយមិនអាចផ្ញើសំបុត្រចេញចូលបានទៀតឡើយ។

# Huy Romduol

For ten years, Romduol has been working to strengthen communication between government officials, citizens, community leaders, and NGO staff. Through looking at local case studies, her workshops use points of disagreement as places to develop problem solving and communication skills. She focuses on helping participants explore their own issues of trust and understanding. Romduol is a senior program officer and training team leader for Working for Peace (WFP), a social development program under the Cambodian Development Resource Institute. She has dedicated herself to the program's success and continuation, explaining that, "Cambodians must be able to communicate across divides. That way we can strengthen relief, advocacy, and peace work."

When asked why she has spent her career in social development, she said, *"I was needed to help the country. I was more educated than many. I do this because I love my country."*

As a young woman in 1972, Romduol was sent to Phnom Penh to further her education. However, after one year of university study, the money her parents mailed stopped arriving. The capital was cut off from Battambang province, as National Road 5 became the frontline of the fighting between the government army and the Khmer Rouge; land travel became too dangerous and mail was impossible to send. Romduol quit school and found herself a job as a stewardess aboard Air Cambodge, flying the skies over Cambodia, Vietnam, and Thailand while the fighting progressed on the ground. *"When I flew I didn't think about things a lot. Just work and earning money. I was very lucky."* In 1975 she was caught up in the whirlwind of the Khmer Rouge.




*រំដួលឈប់រៀន ហើយរកបានការធ្វើជាអ្នកបំរើតាមយន្តហោះខ្មែរអាកាសចរ ហោះនៅប្រទេសខ្មែរ ប្រទេសវៀតណាម នឹងប្រទេសថៃ ពេលប្រទេសខ្មែរកំពុងមានសង្គ្រាម។ "ពេលខ្ញុំនៅលើអាកាសខ្ញុំមិនសូវគិតគូរពីរឿងអ្វីទេ គិតតែពីធ្វើការដើម្បីបានលុយ។ ខ្ញុំមានសំណាងល្អណាស់"។ នៅឆ្នាំ ១៩៧៥ គាត់បានយល់ទាន់នូវសកម្មភាពរបស់ខ្មែរក្រហម*

*នៅពីលើកិច្ចការជាសកម្មជន រំដួលជាម្តាយរបស់កូនពីរនាក់៖ "គឺមានការអស់កំលាំងជាខ្លាំង ប៉ុន្តែខ្ញុំត្រូវតែធ្វើ"។ រំដួលយល់ថាភារកិច្ចរបស់គាត់នឹងការចិញ្ចឹមកូនគាត់ គឺសំខាន់ដូចគ្នា គឺដូចជាការជួយកសាងប្រទេសជាតិក្នុងបច្ចុប្បន្នដែលមានប្រយោជន៍ពីព្រោះនឹងមានអ្នកស្រករក្រោយចាំទទួលមរតកនេះ។*

On top of being a peace activist, Romduol is a working mother of two: *"it is tiring, but I have to do it."* Romduol understands that her responsibility to her work and to raise her children are equally important, as helping rebuild Cambodia in the present is only worthwhile because there is a future generation to inherit it.



# ធីតា ឃិះ

"គ្មានដំណឹងអ្វីចេញពីស្រុកខ្មែរទៀតឡើយ បន្ទាប់ពីគេបិតព្រំប្រទល់ ដែននៅចុងខែឧសភា ឆ្នាំ១៩៧៥" លោកស្រីធីតារំលឹកពីជីវភាពរស់នៅក្នុងប្រទេសថៃពេលប្រទេសកម្ពុជាធ្លាក់ក្នុង អំណាចកុម្មុនីស្ត។ "ខ្ញុំលែងបានទទួលដំណឹងពីគ្រួសារខ្ញុំពីរខែមុននោះ ហើយមិនដែលនឹកស្មានថាគ្រួសារខ្ញុំត្រូវរស់នៅក្នុងរបបឃោរឃៅដូច្នេះឡើយ"។ នៅឆ្នាំ ១៩៧៩ លោកស្រីធីតាចាប់ផ្តើមធ្វើការផ្នែកខាងជនភៀសខ្លួនជាមួយស្ថានទូតអាមេរិកប្រចាំក្រុងបាងកក ប្រទេសថៃ ក្នុងការសង្ឃឹមថានឹងរកឃើញគ្រួសារលោកស្រីឡើងវិញ។ លោកស្រីខំខ្នះខ្នែងបញ្ចុះបញ្ចូលរដ្ឋាភិបាលថៃឲ្យឈប់បណ្តេញប្រជាជនខ្មែរភៀសខ្លួនទៅប្រទេសខ្មែរវិញ។ ក្នុងការផ្សព្វផ្សាយឈ្មោះរបស់ជនភៀសខ្លួនទៅគ្រួសារនៅប្រទេសផ្សេងៗទៀត ក្រុមរបស់លោកស្រីខំធ្វើការបញ្ចុះបញ្ចូលស្ថានទូតទាំងអស់ឲ្យទទួលស្គាល់ទំហំរបស់កិច្ចការនេះ នឹងឲ្យចាត់ចែងចាប់ផ្តើមជាសកម្មភាពឡើងភ្លាម។

"ខ្ញុំនៅចាំឃើញគ្រួសារខ្ញុំនៅជាមួយជនភៀសខ្លួនឯទៀត។ ខ្ញុំសែនតក់ស្លុតដោយឃើញភាពដូចគ្នារវាងគ្រួសារខ្ញុំនឹងជនភៀសខ្លួនទាំងអស់ ព្រោះពោះអ្នកទាំងអស់គ្នាឡើងធំ ខោអាវក្រខ្វក់ សក់ឡើងក្រហមដោយសារការខ្វះជីវជាតិ ហើយស្គមមែនទែន។ នៅក្នុងជំរុំនេះខ្ញុំចាប់ផ្តើមយល់ថា យើងទាំងអស់គ្នាជាមនុស្ស យើងទាំងអស់គ្នាដូចគ្នា...ជនភៀសខ្លួនឯទៀតក្លាយទៅជាអ្នកនៅក្នុងចំណោមគ្រួសារខ្ញុំ"។ លោកស្រីធីតាពន្យល់ថាលោកស្រីធ្លាប់យល់ថាអ្នកដែលក្រពីព្រោះគេខ្ជិល ប៉ុន្តែភាពដូចគ្នាដែលលោកស្រីបានឃើញ បានបង្រៀនលោកស្រីថា មានអ្វីៗឯទៀតដែលសំខាន់ជាងការព្យាយាមខំធ្វើការដើម្បីស្ថានភាពនៃជីវិត។

# Khus Thida

*"All news stopped coming out of Cambodia when the border was sealed toward the end of May [1975],"* Thida recalled of her experience living in Thailand while Cambodia fell to communism. *"I lost contact with my family two months before that and had no idea of the cruelty they were living through."* In 1979, Thida began working for the refugee service in the American Embassy in Bangkok, Thailand, hoping to find her family.She dedicated her efforts to convincing the Thai government to end the forceful return of Cambodian refugees back into Cambodia. By distributing the names of refugees with family in other countries, her team worked to convince embassies to acknowledge the magnitude of the issue and take action.

*"I remember seeing my family among the other refugees. I was shocked that there was no difference between them and other people – all had big stomachs, dirty clothes, red hair from malnourishment, and were very skinny. In that camp, I realized that we are all human, we are the same…the other refugees became my extended family."* Thida explained that she used to think people were poor because they were lazy, but the sameness that she saw taught her that there are things much greater than a person's work ethic that determine their situation in life.

After her return to Cambodia in 1992, Thida initiated a volunteer program to address the severe lack of human resources for Cambodia's reconstruction. She brought Cambodian American volunteers to teach skills for rebuilding the country's institutions; they helped manage civil society groups, develop curriculum for the university, and organize government ministries. In the 1990s, she advocated for non-violent

បន្ទាប់ពីលោកស្រីបានត្រឡប់មកប្រទេសខ្មែរវិញ ក្នុងឆ្នាំ១៩៩២ លោកស្រីធីតា ចាប់ផ្តើមកម្មវិធីស្ម័គ្រចិត្តមួយ ឲ្យគិតគូរអំពីការខ្វះខាតដ៏ខ្លាំងនៃធនធានមនុស្សដើម្បីកសាងប្រទេសខ្មែរ។ លោកស្រីនាំខ្មែរអាមេរិកាំងស្ម័គ្រចិត្ត (Cambodian American volunteers) មកបណ្តុះបណ្តាលជំនាញសំរាប់កសាងឡើងវិញនូវស្ថាប័នរបស់ប្រទេសជាតិ អ្នកស្ម័គ្រចិត្តទាំងនេះ បានជួយរៀបចំក្រុមសង្គមស៊ីវិល ជួយបង្កើនកម្មវិធីសិក្សាសំរាប់សកលវិទ្យាល័យ នឹងជួយរៀបចំក្រសួងរដ្ឋបាល។ នៅឆ្នាំ ១៩៩០ លោកស្រីជួយពង្រឹងសកម្មភាពអហឹង្សា ទទួលភារកិច្ចជាទីប្រឹក្សារបស់ពន្លឺខ្មែរដើម្បីទទួលខុសត្រូវក្នុងពិធីធម្មយាត្រា ( ការធ្វើដំណើរទូរទាំងប្រទេសដើម្បីសន្តិភាព) នឹងនៅឆ្នាំ ១៩៩៨ មានភារកិច្ចជាអ្នករៀបចំការបង្រួបបង្រួមមេត្តាធម៌ទូរទាំងប្រទេស លោកស្រីធ្វើការប្រមូលផ្តុំការគាំទ្រដើម្បីការបោះឆ្នោតដោយសន្តិភាព។ សព្វថ្ងៃនេះ លោកស្រីជាស្ថាបនិកនឹងជានាយកដ្ឋានប្រតិបត្តិនៃសីលការដែលជាអង្គការក្រៅរដ្ឋាភិបាល ដែលសំរាប់បន្តរកកិច្ចការដែលលោកស្រីបានចាប់ផ្តើមតាំងពីដំបូង។

ពេលសួរថា ហេតុអ្វីលោកស្រីជ្រើសរើសយកកិច្ចការនេះ លោកស្រីពន្យល់ថា លោកស្រីមិនបានរស់នៅក្នុងជំរុំភៀសខ្លួនមែន ប៉ុន្តែលោកស្រីបានរស់នៅនឹងកំពុងតែរស់នៅជាមួយផលវិបាកនៃជំរុំភៀសខ្លួន។ "ទោះជាខ្ញុំបានចូលរួមឬមិនបានចូលរួមក៏ដោយ ការសំរេចចិត្តលើការបង្កើតច្បាប់មានឥទ្ធិពលមកលើជីវិតខ្ញុំ"។ គេមិនអនុញ្ញាតឲ្យខ្ញុំនៅពីខាងក្រៅទេ..." សព្វថ្ងៃនេះកិច្ចការរបស់លោកស្រីច្រើនជាងមុខងាររបស់លោកស្រីទៅទៀត គឺជាស្ថានភាពដែលកំណត់អនាគតរបស់លោកស្រី។ ចំពោះយុវជនជំនាន់ក្រោយ លោកស្រីធីតាផ្តល់ឱវាទឲ្យចេះពិចារណា កុំខ្លាច មិនហ៊ានសួរ នឹងមិនហ៊ានផ្លាស់ប្តូរការសន្និដ្ឋានរបស់ខ្លួន។ លោកស្រីនិយាយថាជាការសំខាន់ យុវជនជំនាន់ក្រោយត្រូវគិតដល់ទស្សនះរបស់ខ្លួន នេះគឺជាការរួមចំណែកដ៏ចាំបាច់ លើការយល់ដល់ស្ថានភាពរបស់ខ្លួនក្នុងជីវិតនឹងការផ្តល់សេចក្តីប្រាថ្នាទៅអនាគត។



action, serving as advisor to Ponleu Khmer to oversee the celebrated Dhammayietra (nation-wide peace marches), andin 1998 as the national coordinator for the Methathor coalition, shemobilized support for peaceful elections.Currently she is the founder and executive director of SILIKA, a non-governmental organization that continues the capacity building work she began from the start.

When asked why she chose to pursue this type of work, Thida explained that she did not live through the labor camps, but that she has lived and is living through its consequences.*"Whether or not I was involved, the decision of policy makersaffected my life. I was not exempt…"* Today her work is more than a job, it is a way to determine her own future.To the younger generation, Thida advises them to be reflective, to not be afraid of questioning and changing their assumptions. She says that it is important they consider their own perspective –it is a necessary part of understanding their situation in life and making dreams for the future.



# មាស សូកែវ

សូកែវនិយាយថាបើគិតឲ្យមែនទែនទៅ ការរស់នៅក្នុងសហគមន៍ចាមមានការងាយស្រួលជាងការរស់នៅក្រៅពីសហគមន៍នេះ៖ "ជាមួយប្រជាជនចាមខ្ញុំមានអារម្មណ៍ ថាខ្ញុំមានសុវត្ថិភាពក្នុងការបញ្ចេញយោបល់។ ខ្ញុំអាចនិយាយពីអនាគតខ្ញុំពីសហគមន៍ យើង ពីសាសនាយើង ហើយខ្ញុំមិនមានការភ័យខ្លាចពីការគំរាមកំហែងឡើយ... បើនៅខាងក្រៅសហគមន៍នេះវិញវាមិនមានភាពដូចគ្នាទេ"។ គាត់ពន្យល់ថាជនជាតិខ្មែរអុីស្លាម ជាក្រុមជនជាតិនឹងសាសនាភាគតិចនៃប្រទេសកម្ពុជា រស់នៅក្នុងសហគមន៍ដែលពោរពេញដោយសន្តិភាព ហើយភាគច្រើនមិនមានគំរោងការទៅធ្វើអាជីវកម្មឬទៅរៀនបន្តនៅខាងក្រៅសហគមន៍នេះទេ ភាគច្រើនពីព្រោះគេមិនចង់ប្រឈមមុខនឹងការរិះគន់ នៃការអនុវត្តសាសនានេះ។ ការជំរុញចិត្តរបស់សូកែវឲ្យចេញពីផ្ទះគឺទៅរៀនសូត្រដើម្បីរកការងារណាដែលងាយស្រួល ការងារដែលមិនត្រូវប្រើកំលាំង។ អ្វីដែលគាត់រកឃើញនៅក្នុងទីក្រុងគឺសេចក្តីស្រឡាញ់នៃទស្សនះវិស័យនឹងវប្បធមិ ដែលមានលក្ខណះខុសៗគ្នា ដែលជាបទពិសោធន៍ដែលគាត់ចង់ចែករំលែកជាមួយអ្នកឯទៀត។

សូកែវធ្វើការដើមបីរួមបញ្ចូលសហគមន៍ចាមជាមួយនឹងប្រជាជនទូរទៅក្នុងប្រទេសកម្ពុជាដ៏ធំធេង។ "យើងចង់រស់នៅក្នុងភាពសមរម្យ ហើយបើយើងរស់នៅដោយឡែកៗពីគ្នាដោយគ្មានទំនាក់ទំនងនឹងគ្នាក្នុងសង្គមទេ គឺពិតជាមានការទំនាស់ដ៏ធំដែលនឹងកើតមានឡើងដោយសារតែការយល់ច្រឡំ។ គឺប្រហែលជាមានការពិបាកពេលមនុស្សម្នាក់ៗជួបគ្នាជាដំបូងក្នុងការនិយាយឬការប្តូរទស្សនះគ្នាប៉ុន្តែគេត្រូវតែមានការព្យាយាម។ វានឹងកាន់តែស្រួលឡើង"។

# Meas Sokeo

Sokeo said that in many ways, it would have been easier to live inside the Cham community than outside it: *"With other Cham feel safe to share my thoughts. I can talk about my future, our community, our religion, and I do not feel threatened…outside it is different."* He explained that Cham Muslims, an ethnic and religious minority in Cambodia, live in peaceful communities and usually do not venture outside them to do business or get more schooling, many times because they face discrimination for their religious practices. Sokeo's initial motivation to leave home was to get educated for an "easy" job, one that didn't require hard labor. What he found in the city though, was a love for different perspectives and cultures - an experience he wanted to share with others.

Sokeo works to integrate Cham communities and individuals into the greater Cambodia: *"We want to live in harmony. If we live separately, without good relationships with others, there will beconflict because of misunderstandings. It might be difficult for people meeting the first time to talk or share their perspectives, but they have to work through that. It gets easier."*

As the executive director for the Alliance for Conflict Transformation (ACT), Sokeo hopes to improve cooperation between civil leaders across religious, ethnic, and geographical divides. The Alliance for Conflict Transformation, a non-governmental organization established in 2002 to help facilitate sustained country development, focuses on building cooperative skills in civil leaders. In his ten years with

ក្នុងថានះជានាយកដ្ឋានប្រត្តិបត្តិរបស់ក្រុមការងារដើម្បីដោះស្រាយទំនាស់ សូកែវសង្ឃឹមថា នឹងកែលំអសហប្រតិបត្តិការរវាងអ្នកដឹកនាំស៊ីវិលនៃសាសនា ជាតិពន្ធនឹងតំបន់ផ្សេងៗទាំងអស់។ ក្រុមការងារដើម្បីដោះស្រាយទំនាស់( ACT ) ជាអង្គការក្រៅរដ្ឋាភិបាល បង្កើតឡើងនៅឆ្នាំ ២០០២ ដើមបីជួយសំរួលការ អភិវឌ្ឍន៍របស់ប្រទេសដែលមានគោលការណ៍ ក្នុងការស្ថាបនាជំនាញខាងសហ ប្រតិបត្តិការនៃអ្នកដឹកនាំស៊ីវិល។ នៅក្នុងរយះពេល ១០ ឆ្នាំជាមួយក្រុមដឹកនាំនេះ សូកែវជាគន្លឹះសំខាន់នៃការពង្រីកកម្មវិធីនៃការទទួលមើលការខុសត្រូវសកម្មភាព ក្នុងសហគមន៍នៃខេត្តជាច្រើននៅក្នុងប្រទេសកម្ពុជានឹងរក្សាមិត្តភាពជាមួយក្រសួង អប់រំនឹងវិទ្យាស្ថានឯទៀតៗផង។ គាត់ជាអ្នកផ្តើមបង្កើតគម្រោងស្ថាបនាសន្តិភាព រវាងជាតិពន្ធនាៗ ( the Inter-Ethnic Peacebuilding Project ( IEPB ) )ដែលជា មធ្យោបាយសំរាប់បង្កើតការចាប់អារម្មណ៏ពីការគោរព នឹងពីវប្បធម៌នៃអ្នកដឹក នាំសង្គមស៊ីវិល។

ពីព្រោះបទពិសោធន៍ផ្ទាល់របស់គាត់ជាមួយការរិះគន់នៃជាតិពន្ធនឹងសាសនា គាត់មើលឃើញ ACT "ជាកន្លែងដែលខ្ញុំអាចសំរួលចិត្តនឹងធ្វើការសំរាប់អ្នកឯទៀត មិនគ្រាន់តែជាសំរាប់សហគមន៏ខ្ញុំទេ ក៏ប៉ុន្តែជាសំរាប់ក្រុមផ្សេងៗទៀតដែលទទួល រងគ្រោះដោយសារការរិះគន់"។ ពេលសួរថាគាត់បានរៀនសូត្រអ្វីខ្លះពីការធ្វើការ ជាមួយប្រជាជនដែលមានជំនឿនឹងមានបទពិសោធន៍ខុសៗគ្នា សូកែវឆ្លើយថា "បានធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកឯទៀតខ្ញុំគិតពីការគោរពគ្នាខុសពីមុន។ ខ្ញុំប្រើ ពាក្យស្វាគមន៏របៀបពុទ្ធសាសនាពេលខ្ញុំស្វាគមន៏អ្នកកាន់ព្រះពុទ្ធសាសនា អ្នកខ្លះ ថាអ្នកកាន់សាសនាអ៊ីស្លាមមិនត្រូវធ្វើដូច្នេះទេ ប៉ុន្តែខ្ញុំមើលឃើញថានេះជារបៀប មួយដើមបីបង្ហាញការគោរពគ្នា"។ ដោយអនុវត្តការគោរពគ្នានឹងដោយមានចិត្ត ទូលាយ សូកែវបានបង្ហាញជាគំរូដល់ខ្មែរទាំងអស់ ក្មេងឬចាស់ ឲ្យធ្វើដំរាប់តាម។



ACT, Sokeo has been key to the programs' expansion, overseeing its outreach to several of Cambodia's provinces and maintaining its partnerships with the Ministry of Education and other institutions. He initiated the Inter-Ethnic Peacebuilding Project (IEPB) as a way to build respect and cultural awareness in civil society leaders.

Because of his own experiences with ethnic and religious discrimination, he sees ACT as a *"place where I can heal myself and do something for others, not only for my own community but also for other groups who suffer from discrimination."* When asked what he has learned from working with people of different faiths and backgrounds, Sokeo says, *"Having to work closely with others, I think about showing respect differently. I use the Buddhist way of greeting when I greet Buddhists – some saya Muslim should not do this, but I see it as a way of showing respect."* By practicing respect and open-mindedness, Sokeo sets an example for all Cambodians, young and old alike.



# ណែប ស៊ីនថៃ

ស៊ីនថៃ ចាប់ផ្តើមការងាររបស់គាត់ជាមួយការបន្ថយអាវុធនៅពេលចុងឆ្នាំ ១៩៩៨ ដោយធ្វើការក្នុងវិស័យនេះដើម្បីសិក្សាអំពីភាពអាចធ្វើបានក្នុងការបន្ថយអាវុធនៅក្នុងសង្គមស៊ីវិលនៃប្រទេសកម្ពុជា។ គាត់មានប្រសាសន៍ថា "ខ្ញុំចូលរួមក្នុងការស្រាវជ្រាវនេះដោយសារខ្ញុំមានការបារម្ភអំពីភាពកើនឡើងនូវការប្រើប្រាស់អាវុធក្នុងប្រទេសខ្មែរ"។ គាត់ពន្យល់ថា ការជាក់ស្តែងជាងគេគឺនៅចន្លោះឆ្នាំ១៩៩៣ទៅ ១៩៩៨ គឺជាឆ្នាំដែលអង្គការសហប្រជាជាតិធានាមើលការខុសត្រូវការបោះឆ្នោត នឹងរដ្ឋប្រហានៅពេលដែលការប្លន់ដោយអាវុធជម្លោះវាយតប់គ្នា នឹងការឈ្លោះគ្នាបន្តិចបន្តួចដែលភាគច្រើនជាទីបញ្ចប់មានការរបួសដោយគ្រាប់កាំភ្លើង។

ការចូលរួមរបស់ស៊ីនថៃ ក្នុងការសិក្សាពីបញ្ហានេះ គឺជាការសំខាន់បំផុតក្នុងឋានៈគាត់ជាអ្នកសំរបសំរួលរវាងអ្នកលក់ដូរអាវុធនឹងអ្នកធ្វើការស្រាវជ្រាវ។ "ខ្ញុំប្រើបទពិសោធន៍ដែលខ្ញុំមានពេលខ្ញុំនៅធ្វើជាទាហ៊ានទ័ពព្រៃទៅបង្កើតឲ្យមានការទុកចិត្តគ្នាទៅវិញទៅមក។ ខ្ញុំប្រើពាក្យដែលចាំបាច់ ហើយនិយាយអំពីពេលមានសង្គ្រាមនឹងរឿងខ្លះដែលនាំឲ្យគេសើចរីករាយ។ គេមិនមានអារម្មណ៍ថាត្រូវមានការគំរាមកំហែង ហើយគេប្រាប់ខ្ញុំពីដំណឹងដូចជាការងាយរកបាននូវអាវុធប្រភេទខ្លះ ហើយតើអាវុធនោះចេញមកពីប្រភពណា"។

មុនពេលគាត់ចាប់ផ្តើមការតស៊ូមតិនេះ ស៊ីនថៃ ជាក្មេងជំទង់ក្នុងទ័ពព្រៃធ្វើសង្គ្រាមដើម្បីរំដោះប្រទេសកម្ពុជាពីការកាន់កាប់របស់ប្រទេសវៀតណាម។ បទពិសោធន៍គាត់ពីគ្រឿងអាវុធ នឹងបេសកកម្មដាក់គ្រាប់បែក ជំរុញឲ្យគាត់មានការប្រឹងប្រែងយ៉ាងខ្លាំងក្នុងការប្រមូលអាវុធ៖ "ពេលខ្ញុំកាន់អាវុធខ្ញុំអាចដើរម្នាក់ឯងនៅក្នុងព្រៃ។ ខ្ញុំអាចហ៊ាន

# Neb Sinthay

Sinthay began his work with weapons reduction in late 1998, doing fieldwork for a study on the feasibility of removing guns in Cambodian civil society. He says, *"I joined the research because I was worried about the increase in gun-use in Cambodia."* He explains that it was especially apparent between1993 and 1998, the years between the UN sponsored elections and the coup d'etat, when armed robberies, brawls, and small conflicts would often end in bullet wounds. Sinthay's participation in the study was crucial, as he was the mediator between arms dealers and the researchers: *"I used my experience as a guerilla soldier to make them comfortable – I used the right terminology and we shared stories about war time and joked around. They did not feel threatened, and they told me information like how available certain weapons were and where they were coming from."*

Before he began his advocacy work, Sinthay was a teenage guerilla soldier fighting to liberate Cambodia from Vietnamese occupation. His experience with firearms and bombing missions motivated his extensive effort in weapons collection: *"When I carried a gun, I could walk alone into the forest. I made riskier decisions because it protected me. Without my gun I did not walk alone."* Sinthay explains that possessing a gun can change a person's thinking for the worse; considering Cambodia's long history of war, he fears that without intervention, future generations will continue to resort to violent solutions.

Sinthay went on to work towards weapons education, collection, and law reform, becoming the director of the Working Group for Weapons Reduction. There, he and a team lobbied the government to

ប្រថុយប្រថាន ពីព្រោះអាវុធនេះការពារខ្ញុំ បើគ្មានកាំភ្លើងទេខ្ញុំមិនដើរម្នាក់ឯងក្នុងព្រៃទេ"។ ស៊ីនថៃ ពន្យល់ថា មានកាំភ្លើងនៅនឹងខ្លួនអាចធ្វើឲ្យគំនិតរបស់អ្នកកាន់ទៅជាអាក្រក់បាន។ បើគិតអំពីប្រវត្តិសង្គ្រាមដ៏យូររបស់ប្រទេសកម្ពុជា គាត់ភ័យថា បើមិនធ្វើការអន្តរាគមន៍ទេ ប្រជាជនជំនាន់ក្រោយនឹងបន្តការប្រើប្រាស់អំពើហឹង្សាក្នុងការរិះរកដំណោះស្រាយ។

ស៊ីនថៃ ធ្វើការឆ្ពោះទៅរកការសិក្សាខាងអាវុធ ប្រមូលអាវុធ នឹងការកែទំរង់ច្បាប់ ហើយបានក្លាយទៅជានាយកនៃក្រុមការងារខាងការបន្ថយអាវុធ។ នៅក្នុងលក្ខណះនេះ ហើយដែលគាត់នឹងក្រុមគាត់បានខំបញ្ចុះ បញ្ចូលរដ្ឋាភិបាលឲ្យទទួលស្គាល់ថាការមានអាវុធនៅតាមផ្លូវធ្វើឲ្យមានការបន្ថយការលូតលាស់របស់ប្រទេស។ គេទាំងអស់គ្នាបង្ខំរដ្ឋាភិបាលឲ្យចាប់ផ្តើម កម្មវិធីប្រមូលអាវុធ។ នៅឆ្នាំ១៩៩៩ ក្រសួងមហាផ្ទៃបានរៀបចំទម្រង់ការប្រមែប្រមូលអាវុធទូរទាំងប្រទេស ហើយនៅក្នុងឆ្នាំ២០០៥ រដ្ឋសភាជាតិបានចេញសេចក្តីកត់ត្រាបន្ថែមពីច្បាប់នៃអាវុធបញ្ជាក់ឲ្យច្បាស់លាស់នូវការដាក់ទោសចំពោះជនណាដែលប្រើអាវុធដោយខុសច្បាប់ ឬបង្កើតកាំភ្លើងនឹងគ្រឿងផ្ទុះ។ ស៊ីនថៃបញ្ជាក់ថា "គេបានប្រមូលបានអាវុធជាច្រើន ប៉ុន្តែការ ប្រមូលនេះមិនអាចដោះស្រាយបញ្ហានេះបានទេ សព្វថ្ងៃនេះយើងត្រូវតែមានមូលនិធិ ថែមទៀត ដើម្បីពង្រីកកងជីវពលក្នុងភូមិដើម្បីសុវត្ថិភាពរបស់ប្រជាជន ទើបប្រជាជនអាចទុកចិត្តកងនគរបាលបាន ហើយមិនបាច់ត្រូវការឲ្យមានអាវុធទៀតទេ"។

ស៊ីនថៃ ខំធ្វើការដើម្បីជួយការផ្លាស់ប្តូរពីសង្គ្រាមទៅពេលបន្ទាប់ពីសង្គ្រាម។ គាត់មានជំនឿថា ការលប់បំបាត់គ្រឿងអាវុធអាចបើកទ្វារឲ្យមានការចេះប្រាស្រ័យទាក់ទងគ្នា នឹងគឺជាការចាប់ផ្តើមដើម្បីស្ថាបនាសន្តិភាព។ អំពីសេចក្តីសង្ឃឹមរបស់គាត់ទៅអនាគត ស៊ីនថៃនិយាយថា "ខ្ញុំចង់ឲ្យកូនខ្មែរជាន់ក្រោយកុំគិតពេកពីអ្នកណាត្រូវនឹងអ្នកណាខុសប៉ុន្តែត្រូវខំគិតពីការសំរបសំរួលគ្នា។ ដូចនេះហើយយើងត្រូវធ្វើការចរចារពីការមិនចុះសំរុងគ្នាជាជាងដណ្តើមគ្នាយកឈ្នះធ្វើដូចនេះទើបសន្តិភាពនឹងកើតមានឡើងបាន"។



acknowledge that the presence of weapons in the streets was impeding the country's development; they pressured them to begin a weapons collection program. In 1999, the Ministry of the Interior organized a nation-wide weapons collection procedure, and in early 2005, the national assembly passed an updated weapons law, clarifying the punishment for those who illegally use or produce guns and explosives. Sinthay notes, *"Many weapons were collected, but it does not fix the problem. Now there needs to be more funding to expand village militia, so villages are safe and people can trust the police and have no need to take up weapons again."*

Sinthay is working to ease Cambodia's transition from war to post-war. He believes that the absence of weapons opens the doors for communication and is a starting point for building peace. About his hope for the future, Sinthay says, *"I want young Khmer to think less about who is right and who is wrong and more about compromise. That way conflicts can be negotiated rather than won and a peaceful solution can be made."*



# នៅ កាស៊ី

លោកកាស៊ី ចង្អុលប្រាប់ពីការមិនសមនឹងកើតមានឡើងនូវការចេះនិយាយភាសាអង់គ្លេសរបស់គាត់។ ការចេះភាសាអង់គ្លេសនេះ បានផ្តល់ឲ្យគាត់នូវភាពផ្ទុយគ្នា គឺវាបណ្តាលឲ្យគាត់ទទួលទារុណកម្មក្នុងជីវិត និងក៏ជាទេពកោសល្យសម្រាប់បំរើជីវិតគាត់ដែរ។ ម្យ៉ាងគឺជាមូលហេតុគាត់បានត្រូវគេសង្ស័យថាជាបុគ្គលិក ស៊ីអាយអេ ហើយត្រូវគេធ្វើទារុណកម្មឲ្យសារភាពពេលសម័យខ្មែរក្រហម។ ម្យ៉ាងទៀតគឺជាភាសាដែលគាត់ប្រើសំរាប់ផ្សព្វផ្សាយពីបទពិសោធន៍ក្នុងជីវិតគាត់ដោយធ្វើដំណើរឆ្លងកាត់ពិភពលោកដើម្បីអប់រំអ្នកស្តាប់ទាំងអស់អំពីមនុស្សជាតិនិងសេចក្តីសង្ឃឹម។ លោកកាស៊ីជាអ្នកបង្កើតវិទ្យាស្ថានខ្មែរខាងសិទ្ធិមនុស្សដែលជាអង្គការស៊ីវិល ដែលបានផ្សព្វផ្សាយទៅគ្រប់ខេត្តនូវការបង្ហាត់បង្រៀនពីសិទ្ធិមនុស្ស ដែលបានលូតលាស់រហូតដល់បានត្រូវបញ្ចូលសិទ្ធិមនុស្សក្នុងកម្មវិធីសិក្សាក្នុងសាលារៀនសាធារណៈ។ លោកកាស៊ី ក៏ជាអ្នកគាំទ្រភាពត្រឹមត្រូវនៃកិច្ចអភិបាលនិងលិទ្ធិប្រជាធិបតេយ្យ។ ពីឆ្នាំ ១៩៩៧ ដល់ឆ្នាំ ២០០២ គាត់ជាអនុប្រធាននៃគណៈកម្មាធិការជាតិខាងបោះឆ្នោត ដែលគាំទ្រការបោះឆ្នោតដោយយុត្តិធម៌ និងនៅឆ្នាំ ២០០៤ ជារដ្ឋលេខាធិការខាងតុលាការ។ ក្នុងឆ្នាំ ២០០៦ គាត់លាលែងពីដំណែងខាងនយោបាយហើយត្រឡប់ទៅបង្រៀនភាសាអង់គ្លេសវិញ។

លោកកាស៊ី មានចំណង់ក្នុងការបង្រៀននឹងខាងការទាក់ទងជាមួយយុវជនខ្មែរតាមផ្លូវម្យ៉ាង ដែលផ្តួចផ្តើមគេទាំងអស់គ្នាឲ្យអាចឈមមុខត្រៀមខ្លួនសម្រាប់អនាគត។ គាត់រីករាយពេលឃើញកូនសិស្សគាត់មានការរីកចំរើន "មុនដំបូងពួកគេយល់ ៣ ទៅ ៤ ពាក្យ បន្ទាប់មក ៣ ទៅ ៤ ឃ្លា ហើយបន្ទាប់មកទៀតគេចេះតែងឃ្លាដោយខ្លួនឯង!...គេរៀនភាសាអង់គ្លេសពីខ្ញុំ ហើយប្រហែលជាគេនឹងទៅ

# Neou Kassie

Kassie pointed out the irony in how speaking English had been both a curse and a gift in his lifetime. On one hand, it was the reason he was suspected of being CIA and tortured for confession during the KR era. On the other, it is the language he's used to broadcast his story, traveling across the world to educate audiences about humanity and hope. Kassie is the founder of the Cambodian Institute of Human Rights, a civil organization that has reached out to several provinces with workshops on human rights and made strides to include human rights education in the public school system. Kassie is also an advocate of good governance and democracy. Between 1997 and 2002 he was the vice chairman of the national election committee advocating fair elections and in 2004, a secretary state of justice. In 2006 he resigned from political life and returned to teaching English.

Kassie finds a passion for teaching, for interacting with young Cambodians in a way that prepares them for the future. He gets joy from seeing the students' progress: *"First they understand three or four words, then three or four sentences. Then they make their own sentences!…They learn English from me, and maybe they will go study more abroad. And then they might bring Cambodia up to speed with the rest of the world."*

Kassie is one of few survivors of the KR interrogation system. When asked what was the most important lesson he walked away with, he answered, *"Never lose hope. I never lost hope for survival. Hope kept my brain working…I was able to see opportunities, be creative, and find ways to help myself."* He recalled past times when he had managed to obtain tobacco to trade for traditional medicine, or when he persuaded his 14-year-old jailors to leave him leftover coconuts. From

*បន្តការសិក្សានៅប្រទេសក្រៅ។ ហើយបន្ទាប់មកគេអាចធ្វើឲ្យកម្ពុជាដើរទាន់ប្រទេសផ្សេងៗទៀតក្នុងពិភពលោក"។*

*លោកកាស៊ី ជាអ្នកនៅរស់ដ៏តិចតួចក្នុងចំណោមពួកដែលត្រូវបានសួរចំលើយពីប្រព័ន្ធខ្មែរក្រហម។ ពេលសួរថា អ្វីទៅដែលជាមេរៀនសំខាន់បំផុតដែលគាត់បានរៀនសូត្រ គាត់ឆ្លើយថា "កុំបោះបង់សេចក្តី សង្ឃឹម ខ្ញុំមិនដែលអស់សង្ឃឹមក្នុងការរស់នៅ សេចក្តីសង្ឃឹមធ្វើឲ្យខួរក្បាលខ្ញុំបន្តធ្វើការ...ខ្ញុំអាចមើលឃើញឱកាសដែលហុចឲ្យចេះឆ្នៃប្រឌិត ហើយចេះរកឃើញមធ្យោបាយជួយខ្លួនឯង"។ គាត់រំលឹកពីអតិតកាលពេលគាត់ចេះដោះស្រាយ ដោយយកថ្នាំជក់ទៅដូរយកថ្នាំពេទ្យហ្វក៏គាត់អាចបញ្ចុះបញ្ចូលក្មេងយាមគុកម្នាក់អាយុ ១៤ ឆ្នាំ ឲ្យទុកដូងដែលនៅសល់ឲ្យគាត់។ ពីបទពិសោធន៍ទាំងនេះ គាត់មានជំនឿដ៏ខ្លាំងថាសេចក្តីសង្ឃឹមនាំឲ្យគាត់ចេះឆ្នៃប្រឌិត ហើយការឆ្នៃប្រឌិតនេះនាំមកនូវភាពក្លាហាន នឹងគំនិតដើម។*

*ចំពោះយុវជនជាន់ក្រោយ គាត់ពន្យល់ថា បន្តិចទៀតកំរិតនៃចំណេះវិជ្ជាក្នុងពិភពលោកនឹងកាន់តែខ្ពស់ឡើងជាងសព្វថ្ងៃ។ គឺជាការមិនគ្រប់គ្រាន់ទេសំរាប់និស្សិតឥឡូវនេះដែលបានចេះដឹងត្រឹមតែកំរិតរបស់គ្រូខ្លួនឯង។ គេត្រូវតែចេះឲ្យលើសចំណេះគ្រូរបស់គេ។ ពេលសួរថា តើគាត់យល់យ៉ាងណាពីអនាគតប្រទេសកម្ពុជា លោកកាស៊ីឆ្លើយថា "កម្ពុជាមានធនធានច្រើនណាស់ ភ្នំដើម្បីទំនប់ទឹក ទន្លេដើម្បីអគ្គីសនី និងធនធានជាច្រើនទៀត"។ គាត់សារភាពថា ពេលមានតិចណាស់ចំពោះប្រជាជនស្រករគាត់ដែលនៅធ្វើការបាន ហើយគាត់សង្ឃឹមទៅលើយុវជនជាន់ក្រោយឲ្យប្រើកំលាំងនិងពេលវេលា ដើម្បីបង្រៀនខ្លួនឯងនិងប្រទេសជាតិខ្លួនឯង។ "កំរិតនៃចំណេះវិជ្ជានៅតែខ្ពស់ឡើងជានិច្ច" គាត់មានប្រសាសន៍ "យើងត្រូវតែណែនាំខ្លួនឯងឆ្ពោះទៅអនាគត ហើយត្រូវតែសំដៅទៅរកគោលបំណងណាដែលខ្ពស់"។*




such experiences, he strongly believes that hope lead him to creativity while creativity led him to courage and initiative.

To young Cambodians, he explains that soon, the level of knowledge in the world will be much higher than it is today. *"It is not enough for students today to be satisfied with knowing as much as their teachers. They need know beyond what their teachers know."* When asked about where he saw Cambodia in the future, Kassie says *"Cambodia has many resources: mountains for dikes, rivers for hydroelectricity, and much more."* He admits that there is little left his generation can do and so looks to young Cambodians to use their energy and time to educate themselves and their country. *"The level of knowledge is always rising,"* he says. *"You have to orient yourself towards the future and aim high.*

# សេក សារុំ



សារុំ ស្គាល់ប្រទេសខ្មែរតាមរយៈការពិពណ៌នារបស់លោកគ្រូនាង។ នាងមិនដែលឃើញវាលចំការទីវាលលិចទឹក ឬភូមិនានាទេ ប៉ុន្តែនាងឮសួរថាស្រុកខ្មែរស្អាតណាស់។ នាងកើតនៅឆ្នាំ ១៩៧៩ ក្នុងជំរុំ០០៧ ជំរុំជនភៀសខ្លួនតាមព្រំដែនខ្មែរ-ថៃ។ ជីវិតនាងពេលនោះមិនដែលស្គាល់ការបែងចែកវណ្ណៈនៅក្នុងសង្គមឡើយ។ ជនភៀសខ្លួនពេលនោះត្រូវបានទទួលសំភារៈដូចៗគ្នាសំរាប់សង់ផ្ទះនិងទទួលម្ហូបអាហារស្មើគ្នាសំរាប់ចិញ្ចឹមកូនក្មេង។ កាលនៅជាកុមារីនាងមានម្ហូបគ្រប់គ្រាន់សំរាប់ទទួលទាន នាងមានក្មេងៗឯទៀតជាច្រើនគ្រាន់នឹងលេងជាមួយ ហើយមានទាំងបណ្ណាល័យដែលបង្ហាញនាងឲ្យស្គាល់ពិភពលោកនៅក្រៅជំរុំផង។ គឺជាជីវិតដ៏ល្អប្រសើរ។

សារុំ បានស្គាល់ប្រទេសខ្មែរជាដំបូងនៅឆ្នាំ១៩៩៣ ពេលនាងមានអាយុ ១៤ឆ្នាំ។ គ្រួសារនាងបានធ្វើមាតុភូមិនិវត្តមកខេត្តបាត់ដំបង។ គឺមិនដូចគំនិតដែលនាងបាននឹកស្មានឡើយ។ តាមផ្លូវទៅផ្ទះថ្មីរបស់នាងពោរពេញទៅដោយផ្លូវដែលត្រូវខូចខាតដោយសារគ្រាប់បែក។ គ្មាននរណាយកម្ហូបអាហារមកចែកឲ្យគ្រួសារនាងទៀតទេ គ្រូបង្រៀនដែលក្រទទួលយកសំណូកពីកូនសិស្ស ហើយគេដាក់ឈ្មោះជនភៀសខ្លួនថាជាជនក្បត់សង្គម។ ការបាញ់គ្នាចុះឡើងពេលនោះគឺជាការធម្មតា ហើយអ្នកដែលរត់ចេញពីទីលំនៅខ្លួនឯងដោយសារសង្គ្រាមបានមកស្នាក់នៅពាសពេញក្បែរផ្ទះរបស់នាង (ភូមិដែលនៅជិតតំបន់ប៉ៃលិននៅជាមូលដ្ឋានរឹងមាំរបស់ខ្មែរក្រហមរហូតដល់ឆ្នាំ១៩៩៨)។ គឺពិតជាមិនមែនកន្លែងដ៏ល្អប្រសើរឡើយ។ សារុំនិយាយថា ចំណែកដែលពិបាកខ្លាំងជាងគេគឺការស្វែងរកការសិក្សាដោយគ្មានលុយ

# Sek Sarom

Sarom only knew of Cambodia through her teachers' descriptions. She had never seen its fields, flooded plains, or villages, but she'd heard it was beautiful. Sarom was born in 1979 at Camp 007, a refugee center on the Cambodian-Thai border. Growing up she did not see class divisions. Refugees had been given the same materials to build their house and the same portions to feed their children. As a child, she had enough to eat, plenty of other children to play with, and even a library that showed her a world outside the fence. *"It was a good life."*

Sarom saw Cambodia for the first time in 1993 when she was 14 as her family was repatriated to Battambang province. It was not as she had imagined. Bomb-blasted roads led her to her new home; there were no food handouts; poor teachers accepted bribes from students; refugees were labeled as outsiders; fire fights were common and displaced people sheltered near her home (neighboring province Pailin would remain a KR stronghold until 1998). It was not beautiful. Sarom says the most difficult part was trying to get an education with no money, no role models, nor a system that rewarded honest work.

In 1997, Sarom took a class about peace offered by an American at a local temple. Although she was only looking to learn English, she found herself exposed to the lives of Aung Sang Suu Kyi, Martin Luther King Jr., Nelson Mandela, Mahatma Gandhi, and Maha Ghosananda. Inspired by these men and women, she began to apply their principles in her own life. She looked around and saw suffering. Saw corruption in the judicial system, where rich criminals could evade internment and poor criminals, often with less severe crimes, would be put in jail. *"If people do not believe peace is possible, it will never be possible."* Rather than accept that peace in Cambodia would never come, Sarom decided that


PEACE EAGLE
NO TO WAR
people building peace
people building peace
USAID


ការិយាល័យសិក្សា
ការិយាល័យ
ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

កាក់ គ្មានអ្នកណាជាជនគំរូ នឹងគ្មានប្រពន្ធ័ដែលផ្តល់រង្វាន់ចំពោះការធ្វើការដោយស្មោះត្រង់។

នៅក្នុងឆ្នាំ ១៩៩៧ សារុំបានរៀនថ្នាក់មួយអំពីសន្តិភាពដែលបានបង្រៀនឡើងដោយជនជាតិអាមេរិកាំងម្នាក់ នៅក្នុងវត្តមួយក្នុងស្រុកនាង។ គំនិតនាងគឺមានបំណងសំឡឹងរករៀនភាសាអង់គ្លេសតែនាងទៅជាបានទទួលនូវបទពិសោធន៍ពីជីវិតរបស់ Aung Sann Suu Kyi, Martin Luther King Jr., Mahatma Gandhi, and MahaGhosananda. ទៅវិញ។ អ្នកទាំងនេះបានជំរុញចិត្តនាងឲ្យយកជាមេរៀនសំរាប់ជីវិតនាងផ្ទាល់។ នាងមើលទៅជុំវិញខ្លួននាង នាងឃើញតែការឈឺចាប់នឹងទុក្ខវេទនា។ នាងឃើញអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាកា ដោយជនល្មើច្បាប់ដែលមានលុយអាចគេចវេសការឃុំឃាំងបាន តែជនល្មើសច្បាប់ដែលគ្មានលុយភាគច្រើនប្រព្រិត្តកំហុសតិចជាងតែទៅជាត្រូវជាប់គុកទៅវិញ។ "បើមនុស្សមិនជឿថាសន្តិភាពអាចកើតមានឡើង គឺថាវាពិតជាមិនអាចកើតឡើងបានមែន"។

ពេលសួរថា នាងមានមធ្យោបាយយ៉ាងណាសំរាប់ផ្គត់ផ្គង់ខ្លួនឯងនឹងឪពុកម្តាយនាង បើនាងគ្មានប្រាក់ខែនឹងនរ។ សារុំឆ្លើយថា កិច្ចការរបស់នាងគឺជាកិច្ចការដែលត្រូវពុះពាររាល់ថ្ងៃ។ "ខ្ញុំចង់ដឹងថាខ្ញុំអាចឈានទៅដល់កំរិតណាក្នុងឋានះជាអ្នកស្ម័គ្រចិត្ត។ នេះជាការល្អណាស់។ មនុស្សភាគច្រើនមិនយល់ទាល់តែសោះ។ ឥឡូវនេះអ្វីៗគឺជារឿងលុយពីព្រោះគេយល់ថាលុយជាចម្លើយរបស់អ្វីៗទាំងអស់។ លុយជាការសំខាន់ ប៉ុន្តែលុយមិនមែនជាចម្លើយរបស់អ្វីៗទាំងអស់ឡើយ"។



peace was possible, and that she would do her part to make it reality. She would take on various opportunities including co-teaching and translating Buddhism in English at Preh Sihanouk Raja Buddhist University, teaching language at the Battambang Provincial Prison, establishing the Battambang Prison Library, organizing food collections during Pchum Bin to redistribute to the hungry, and all the while working side-jobs translating NGO reports for money to help her family. As an activist for the Dhammayeitra movement, she helps provide services monks, youth, and prisoners.

When asked about how she planned to support herself and her parents without a steady income, Sarom responded that her work was a daily challenge. *"I want to see how far I can go as a volunteer. It's beautiful. A lot of people don't understand. Here everything is about money. Because they think money is the answer. Money is important, but it is not the only answer."*



# សុង កុសល

នាងបានដឹងថា នាងជាក្មេងខុសគេនឹងក្មេងឯទៀត។ នាងពន្យល់ថា នាងមិនអាចលេងដូចក្មេងឯទៀតលេង  ហើយនាងគ្មានលក្ខណៈគ្រប់គ្រាន់ដូចក្មេងឯទៀត នាងយកដៃនាងទាំងពីរសំរាប់ជួយនាងឲ្យដើរក្នុងផ្ទះ។ "ចំណែកដែលពិបាកជាងគេគឺការខ្មាស់គេ" នាងពន្យល់។ "ខ្ញុំមិនចង់ឲ្យគេមើលមកខ្ញុំ ហើយឃើញតែពីរឿងខ្ញុំអត់មានជើង... ខ្ញុំមានលិទ្ធភាពជាងភាពពិការរបស់ខ្ញុំ។ ខ្ញុំដូចតែអ្នកឯទៀតដែរ" ។

កុសល កើតនៅឆ្នាំ ១៩៨៤ ជាកូនទី ៤ ក្នុងចំណោមកូនទាំង ៦ នៅក្នុងគ្រួសារអ្នកកសិករ។ ពេលអាយុបាន ៥ ឆ្នាំ នាងត្រូវពិការដោយគ្រាប់មីនផ្ទុះពេលនាងជួយធ្វើការម្តាយនាងនៅក្នុងស្រែ។ ជើងរបស់នាងត្រូវគេកាត់ខ្ពស់ពេក ហេតុនេះមិនអាចប្រើជើងពាក់បាន ហើយសព្វថ្ងៃដើរដោយឈើច្រត់សំរាប់មនុស្សពិការ។ យូរបន្ទាប់ពីគ្រោះថ្នាក់មក បុគ្គលិកម្នាក់នៃកម្មវិធីអន្តរជាតិហយុទ្ធនាករដើម្បីហាមមិនឲ្យធ្វើគ្រាប់មីន ( ICBL ) បានកត់សំគាល់ឃើញនាងនៅមន្ទីពេទ្យបាលរោគនៅបាត់ដំបង។ នៅឆ្នាំ ១៩៩៥ ពេលអាយុបាន ១២ ឆ្នាំ កុសលបានចូលធ្វើការជាមួយ ICBL ក្នុងឋានះជាតំណាងជនរងគ្រោះដោយសារគ្រាប់មីននៅជុំវិញពិភពលោក។

"ខ្ញុំអាចនិយាយ ខ្ញុំអាចជាមនុស្សគំរូ។ ខ្ញុំត្រូវតែធ្វើអ្វីមួយពេលខ្ញុំមានលទ្ធិភាពនឹងធ្វើបាន"។

ICBL ប្តេជ្ញានឹងលុបបំបាត់នូវការផលិតនឹងការប្រើគ្រាប់មីនដែលសំរាប់បំផ្លាញមនុស្សលោក។ ជាមួយកម្មវិធីនេះ កុសលបានធ្វើដំណើរឆ្លងទ្វីបលោក ដើម្បីនិយាយ

# *Song Kosal*

She knew she was different from the other children.  She could not play like they played, and she did not look the same: she used her hands to help move through the house. *"The most difficult part is feeling shy,"* she explained.  *"I don't want people to look at me and see only my missing leg…I am more than that. I am the same as you."*

Kosal was born in 1984, the fourth of six children in a rice farming family. When she was five, she was injured by a landmine while helping her mother in the rice fields. Her leg was amputated too high to allow her to use a prosthetic, and today she walks with a crutch. Years after the incident, a staff member of the international campaign to ban landmines (ICBL) noticed her at a Battambang clinic. In 1995, at the age of 12, Kosal joined ICBL as a representative of landmine victims around the world.

*"I can speak. I can be an example.  I have to do something while i have the chance to."*

ICBL is dedicated to eradicating the production and use of antipersonnel landmines. With the organization, Kosal has traveled across the continents to tell her story, gathering thousands of signatures to support the ban. The culmination of her and ICBL's campaigning efforts came in 1997, when 122 countries signed the mine ban treaty agreeing to prohibit the use, stockpiling, production, and transfer of anti-personnel land mines.  Today, Kosal works full time as the ICBL youth ambassador, spreading awareness in order to help countries fund mine-clearance, improve victims' assistance, and strengthen international cooperation.

ពីប្រវត្តិផ្ទាល់របស់នាង ហើយប្រមូលបានហត្ថលេខារាប់ពាន់នាក់ ដើម្បីគាំទ្រការលប់បំបាត់នេះ។ ការធ្វើដែលសំខាន់បំផុតរបស់នាងជាមួយ ICBL គឺលទ្ធផលនៃការទាមទារនៅឆ្នាំ ១៩៩៧ ពេលប្រទេសទាំង ១២២ ព្រមព្រៀងចុះហត្ថលេខាលើសន្ធិសញ្ញាហាមឃាត់ការប្រើប្រាស់ ការប្រមូលទុក នឹងការរំលែកចែកគ្រាប់មីន ដែលបំផ្លាញមនុស្សលោក។ សព្វថ្ងៃនេះ កុសលធ្វើការពេញម៉ោងជាយុវវ័យតំណាងតាមផ្លូវការរបស់ ICBL ក្នុងការពង្រីកនឹងផ្សាយការចាប់អារម្មណ៍នេះ សូមឲ្យគេជួយជាលុយកាក់ ដើម្បីសំរាប់ដោះមីនសំរាប់ជួយជនរងគ្រោះនឹងសំរាប់ពង្រឹងសហប្រតិបត្តិការអន្តរជាតិ។

"អ្នកណាក៏យំ អ្នកណាក៏សើច" នាងរៀបរាប់អំពីការអប់រំដោយការពិភាក្សាគ្នារវាងជនរងគ្រោះដោយសារគ្រាប់មីន។ "ទាំងអស់គ្នាយំពីព្រោះទាំងអស់គ្នាជាអ្នកក្រ ហើយភាពពិការរបស់គេធ្វើឲ្យការរកស៊ីចិញ្ចឹមជីវិតជាអ្នកស្រែក្នុងភូមិកាន់តែពិបាកឡើងទៀត។ ទាំងអស់គ្នាសើចពីព្រោះទោះជាអ្នកទាំងអស់គ្នាមិនដែលស្គាល់គ្នាក៏ដោយ ក៏គេមានអារម្មណ៍ល្អដោយគ្មាននរណារិះគន់នរណាហើយអាចបញ្ចេញមតិផ្ទាល់ខ្លួនបាន"។ កុសលពន្យល់ថា ជនពិការជាច្រើនរស់នៅក្នុងសហគមន៍ដែលមានជំនឿថាជនដែលពិការមិនអាចធ្វើការបាន "អ្នកពិការជាច្រើនគ្មានការអាម៉ាសមុខណាស់"។ ជាការឆ្លើយតបកុសលធ្វើការគាំទ្រសិទ្ធិចាំបាច់របស់ជនពិការដូចជាសិទ្ធិក្នុងការសិក្សានឹងសិទ្ធិក្នុងការចូលរួមសកម្មភាពក្នុងសហគមន៍។

តាមរយៈការងាររបស់នាងនឹងការបណ្តុះបណ្តាលវិជ្ជាជីវះរបស់ ICBL ជនរងគ្រោះជាច្រើនអាចឆ្លងផុតភាពអាម៉ាសមុខនេះបាន។ ចំពោះប្រជាជនជាន់ក្រោយ កុសលសង្ឃឹមថា ទៅថ្ងៃមុខគ្មានក្មេងស្រីណាមួយនឹងត្រូវគេដាក់ឈ្មោះឲ្យថា "មីកំបុត" ទៀតទេ មិនត្រូវបង្រៀនឲ្យវាយតំលៃមនុស្សតាមសំបកក្រៅឡើយគឺត្រូវបង្រៀនថាអ្នកពិការទាំងនោះក៏ដូចអ្នកឯទៀតដែរ គឺគ្មានអ្នកណាអាចកំណត់លិទ្ធិភាពរបស់គេបានឡើយ។

*"Everyone is crying and smiling,"* she said, describing a seminar attended by landmine victims. *"They are crying because they are poor and their disability makes earning a living in the rice-farming villages very difficult. They are smiling because although they are strangers, they feel safe from judgment [at the seminar] and able to share their feelings."* Kosal explained that many live in communities that assume people with disabilities are incapable of work: *"many feel ashamed,"* she said. In response, Kosal advocates for the basic rights of disabled people, such as the right to accessible education and to be involved in the community.

Through her work and that of IBCL's vocational training program, many more are able to transcend the stigma. For future generations, Kosal hopes that no more children be labeled *"mi-kombak,"* no more be taught that they are defined by their limitations, but rather that they, like anyone else, have limitless possibilities.

**mi-kombak* - a derogatory term for someone who is physically handicapped

# ទូច វ៉ារីន



"នៅឆ្នាំ ២០០១ គេអាចនៅសំគាល់ប្រជាជនដែលជាអតីតខ្មែរក្រហមបាន"។ គេមិនស្លៀកពាក់ខ្មៅដូចមុនទេ  ប៉ុន្តែនៅពាក់ស្បែកជើងកង់ឡានប្រើសំពាយលើខ្នង (សាកាដូ ) ហើយស្រីៗនៅទុកសក់ខ្លី។ ពួកនេះគេមិនសូវមានទំនាក់ទំនងល្អជាមួយអ្នកដទៃដែលមានអត្តសញ្ញាណមិនដូចក្រុមរបស់គេទេ ពីព្រោះគេមានជំនឿថាប្រជាជនដទៃមិនចូលចិត្តពួកគេ  និងចាត់ទុកពួកគេថាជាមនុស្សឃោរឃៅនៅក្នុងសម័យខ្មែរក្រហម ។ ឯខាងអតីតខ្មែរក្រហមគិតទៅលើអ្នកផ្សេងទៀតថាជាពួកមូលធនជាពួកដែលមាននិន្នាការនយោបាយខុសពីពួកខ្លួន។

ឆ្នាំនេះលោកស្រីវ៉ារីនត្រូវបានផ្តល់វគ្គបណ្តុះបណ្តាលស្តីពី ការកសាងសន្តិភាពនៅខេត្តឧត្តរមានជ័យ ដែលជាដំបន់ខ្មែរក្រហមទើបនឹងធ្វើសមាហរណកម្មជាមួយនឹងរដ្ឋាភិបាល ដើម្បីធ្វើការផ្សះផ្សាអតីតខ្មែរក្រហម២ស្រុក គឺស្រុកអន្លង់វែង និងត្រពាំងប្រាសាទដែលពីមុនរស់នៅក្រោមការដឹកនាំ និងគ្រប់គ្រងអំពីសំណាក់អ្នកដឹកនាំខ្មែរក្រហម២រូបមិនមានភាពចុះសម្រុងគ្នា។ ក្នុងឋានះជាអ្នកអប់រំជាមួយវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា(CDRI)ផ្នែកកម្មវិធីអភិវឌ្ឍន៍សង្គម លោកស្រីបានទៅជួយធ្វើការសម្របសម្រួលការផ្សះផ្សានេះ។ លោកស្រីបានរៀបចំវគ្គបណ្តុះបណ្តាលដោយឱ្យអាជ្ញាធរមូលដ្ឋានទាំងពីរស្រុកនេះ ដែលជាអតីតខ្មែរក្រហមមានឱកាសជួបជុំគ្នា  រួមគ្នាដើម្បីផ្លាស់ប្តូរគំនិតនឹងអារម្មណ៍ ជាមួយគ្នាទៅវិញទៅមក ។ "ជាដំបូងអតីតខ្មែរក្រហមម្នាក់មិននិយាយអ្វីឡើយ។ ប៉ុន្តែបន្ទាប់ពីបានស្តាប់ក្រុមអ្នកសម្របសម្រួលដែលមិនមែនជាអតីតខ្មែរក្រហមនិយាយអំពីការភ័យខ្លាចនឹងការឈឺចាប់ ក្នុងអំឡុងពេលខ្មែរក្រហមនៅកាន់កាប់ អតីតខ្មែរក្រហមនេះក៏ចាប់ផ្តើមនិយាយរឿងរបស់គាត់ ប្រាប់មកក្រុមអ្នកសម្របសម្រួលវិញដែរ។ គាត់និយាយអំពីការនឹករលឹកដ៏ខ្លាំងចំពោះប្រពន្ធនឹងកូនប្រុសគាត់ ពេលគេបញ្ជូនគាត់ទៅច្បាំង"។  វគ្គនេះបានធ្វើឱ្យអ្នកចូល

# Touch Varine

*"In 2001, the former Khmer Rouge still dressed like Khmer Rouge. They didn't wear black anymore, but they wore shoes made from tires, carried things in backpack, and the girls kept their hair short. They did not talk to ordinary villagers because they believed those who were not like them were bad people - capitalists with the government."* That year, Varine was sent to Udor Mean Chey, a KR reconciliation zone where former KR had difficulty re-integrating with the village people. As an educator with the Cambodian Development Resource Institute's (CDRI) social development program, she went to help facilitate reconciliation.

She arranged a meeting where villagers and former KR shared their thoughts and feelings: *"At first the man [former KR] did not talk.  But after hearing villagers speak about their fears and suffering when the KR were in power, he shared his own.  He talked about how strongly he missed his wife and son when he was sent far away to fight."* These meetings allowed the communities to come together and focus on their similarities rather than their differences. *"I wanted them to understand each other,"* she said. According to Varine, listening to each other's suffering showed the villagers and former KR their common humanity, a place to begin building trust and reconciliation.

Varine has worked as an educator with CDRI for the past ten years because, *"We've [Cambodians] seen war before, and we don't want to meet it again."* Using case studies identified by CDRI's research as significant issues affecting Cambodia, she teaches target groups skills to identify conflict, analyze its causes, and create strategies for its prevention and resolution. Topics range from water distribution to

រួមជាអតីតខ្មែរក្រហមទាំងអស់គិតពិចារណា ហើយឲ្យធ្វើការចាប់អារម្មណ៍នៅលើភាពដូចគ្នាជាជាងភាពខុសគ្នារបស់ប្រជាជនស្រុកទាំងពីរ ជាពិសេសប្រជាជនរស់នៅក្នុងសង្គមខ្មែរទាំងមូល។ "ខ្ញុំចង់ឲ្យគេទាំងសងខាងយល់គ្នាទៅវិញទៅមក និងយល់អំពីប្រជាជនផ្សេងទៀតដែលមិនមែនជាអតីតខ្មែរក្រហមមានក្រុមលោកស្រីជាអ្នកសម្របសម្រួលវគ្គសិក្សានេះជាដើម" លោកស្រីបញ្ជាក់។ តាមការយល់របស់លោកស្រីវ៉ារីន ការស្តាប់គ្នាអំពីទុក្ខវេទនាទាំងសងខាង បង្ហាញអ្នករងគ្រោះសម័យខ្មែរក្រហម នឹងអតីតខ្មែរក្រហមនូវមនុស្សធម៌រួមគ្នាដែលអាចជំរុញឲ្យមានការកសាងទំនុកចិត្តនឹងផ្សះផ្សាគ្នាទៅវិញទៅមក។

លោកស្រីវ៉ារីន ធ្វើការជាអ្នកអប់រំជាមួយ CDRI បានដប់ឆ្នាំហើយ ពីព្រោះ "យើង (ប្រជាជនខ្មែរ) បានឃើញសង្គ្រាមពីមុន ហើយយើងមិនចង់ឃើញសង្គ្រាមម្តងទៀតទេ"។ ស្របតាមករណីសិក្សារកឃើញតាមការស្រាវជ្រាវរបស់ CDRI ដែលជាបញ្ហាសំខាន់ទាក់ទងទៅនឹងប្រទេសកម្ពុជា លោកស្រីបង្រៀននិងផ្តល់ចំណេះដឹងជូនសិក្ខាកាមឲ្យចេះរកមើលភាពខុសគ្នា ធ្វើការវិភាគរកមូលហេតុ នឹងកសាងយុទ្ធសាស្ត្រដើម្បីការពារទំនាស់នឹងរកដំណោះស្រាយ។ ប្រធានបទរួមមាន ទំនាស់អំពីការគ្រប់គ្រងនិងបែងចែកទឹកនៅក្នុងសហគមន៍កសិករប្រើប្រាស់ទឹក និងអំពើហិង្សាក្នុងគ្រួសារជាដើម ហើយក្រុមអ្នកចូលរួមមានរួមបញ្ចូលមន្ត្រីរាជការតាមសង្កាត់ អ្នកកាសែត នគរបាល នឹងក្រុមផ្សេងៗទៀត។ ដោយការបង្រៀនអ្នកចូលរួមឲ្យមានការប្រុងប្រយ័ត្នក្នុងការវាយស្មានរបស់ខ្លួន ទៅលើមនុស្សគ្នាឯងក្នុងសង្គមនឹងឲ្យចេះមានការយោគយល់ចំពោះបំណងរបស់អ្នកឯទៀត ។ លោកស្រីសង្ឃឹមថានឹងអាចកសាងសមត្ថភាពក្នុងការដោះស្រាយបញ្ហាដោយអហឹង្សា ។ លោកស្រីវ៉ារីន ធ្វើការជាមួយមនុស្សម្នាក់ៗ ហើយជួនកាលលោកស្រីមានអារម្មណ៍ថា កិច្ចការនេះ "ជាការតូចតាចហើយប្រហែលជាមិនមានលទ្ធផលធំដុំទេ" ក៏ប៉ុន្តែលោកស្រីរំលឹកខ្លួនឯងថា ការផ្លាស់ប្តូរមនុស្សម្នាក់ៗមានមុខងារសំខាន់។ "សកម្មភាពនៃមនុស្សម្នាក់ៗអាចក្លាយទៅជាសកម្មភាពរបស់ក្រុមមួយ"។ លោកស្រី

domestic violence and participating groups include commune officials, journalists, police, and more. By teaching participants to be critical of their own assumptions or to consider other people's motivations, she hopes to build their capacity for non-violent problem solving.

Varine works with individuals, and sometimes she feels the work *"is small and may not make a big difference,"* but she reminds herself that change on an individual level has an important role to play. *"The actions of a person can become the actions of a group."* Varine believes that in order to build a country that can resolve its problems without resorting to force, a good place to start is with the perceptions and abilities of ordinary people.

វ៉ារីនមានជំនឿថាដើម្បីកសាងប្រទេសដែលអាចដោះស្រាយបញ្ហាដោយមិនពឹងកំលាំងអំណាច កន្លែងល្អដែលត្រូវចាប់ផ្តើមគឺការមានជំនឿលើសមត្ថភាពរបស់ប្រជាជនទាំងអស់របស់សង្គម។



# យ៉េង វីរៈ

ពេលសួរថា ហេតុអ្វីការសិក្សាជាការសំខាន់ចំពោះគាត់ វីរៈឆ្លើយថា "វាមានតំលៃពីព្រោះយើងអាចយកចំណេះយើងទៅធ្វើការឲ្យគេ ឬ ក៏យកចំណេះយើងទៅប្រើការសម្រាប់ខ្លួនឯង...កាលណាយើងមានចំណេះគ្មាននរណាអាចដណ្តើមយកចំណេះនេះចេញពីយើងបានទេ"។ វីរៈ ជានាយកដ្ឋានប្រតិបត្តិនៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) ដែលជាអង្គការក្រៅរដ្ឋាភិបាលនៅក្នុងស្រុក ដែលសម្រាប់ផ្តល់ដំណឹងទាក់ទងនឹងច្បាប់ចំពោះ សាធារណៈជនកម្ពុជា។ ការប្តេជ្ញារបស់គាត់ក្នុងការកសាងលិទ្ធិប្រជាធិបតេយ្យរបស់ប្រទេសកម្ពុជាឲ្យបានកាន់តែប្រសើរឡើងជាលិទ្ធិផល ពីបទពិសោធន៍របស់គាត់តាំងពីគាត់នៅក្មេង រស់នៅក្នុងប្រទេសក្នុងពេលសង្គ្រាមនឹងបន្ទាប់ពីសង្គ្រាម។ វីរៈនៅនឹកឃើញពីគំរោងការដែលអាចផ្តល់ផលវិបាកដ៏ខ្លាំងចំពោះប្រជាជនសមញ្ញ ពីព្រោះគេមិនបានចូលរួមក្នុងការរៀបចំគំរោងការនោះ។ គាត់នៅចាំអំពីការចាប់ខ្លួនតាមអំពើចិត្ត ការសម្លាប់ដែលមិនបានធ្វើឡើងតាមផ្លូវច្បាប់ នឹងការភ័យខ្លាចចំពោះកងនគរបាលដែលផ្តល់នូវការបំភិតបំភ័យនឹងការឈឺចាប់។ "កាលណាការអយុត្តិធម៌កាន់តែមានច្រើនឡើងការយកអំពើហឹង្សាទៅដោះស្រាយបញ្ហាក៏កាន់តែមានច្រើនឡើងដែរ"នេះហើយដែលខ្ញុំបានឃើញហើយហេតុដូច្នេះហើយបានជាខ្ញុំប្រាប់ខ្លួនឯងថា យើង (ប្រជាជនខ្មែរ) ត្រូវតែធ្វើអ្វីមួយ។

មុនពេលសង្គ្រាមពេលគាត់នៅរៀនក្នុងវិទ្យាល័យ វីរៈបានទៅលេងរាជសកលវិទ្យាល័យនៅភ្នំពេញ ហើយសង្ឃឹមថានឹងក្លាយទៅជានិស្សិតសកលវិទ្យាល័យទៅថ្ងៃមុខ។ ពេលខ្មែរក្រហមឡើងកាន់អំណាច ឆ្នាំ ១៩៧៥ ការសង្ឃឹមនេះក៏ត្រូវបានផ្អាក

# Yeng Virak

When asked why an education was important to him, Virak said, *"It's valuable because you can use it to make a living; you can sell your expertise or employ yourself…once you have an education, no one can take it from you."* Virak is the executive director of the Cambodian Legal Education Center (CLEC), a local NGO that provides legal information to the Cambodian public. His dedication to building a more democratic Cambodia stems from his experiences as a young man living in the country during and after war. Virak recalls policies that had severe consequences for ordinary citizens who had no part in making them. He remembers arbitrary arrests, extra judicial killings, and a deep-seated fear of the police that led to mass intimidation and vulnerability. Virak adds, *"The more injustice people feel, the more they're forced to look to violence to solve the problem…This is what I saw and that's why I told myself we [Cambodians] need to do something."*

Before the war, when he was in high school, Virak would visit the Royal University of Phnom Penh and imagine himself a university student. When the KR came to power in 1975, his dream was cut short. He survived the heavy labor, and when the Vietnamese came, he made his way to the capital. There he found the education and experience that led him to become the activist he is today.

As director of CLEC, Virak oversees the organization's activities: promoting legal education, empowerment, and advocacy to target groups like union leaders, management, and citizens negatively affected by land concession practices.

ចោល។ គាត់បាននៅរស់បន្ទាប់ពីឆ្លងកាត់ពេលកម្មដ៏ពិបាក ហើយពេលយូនចូល ទើបគាត់បានវិលត្រឡប់មករដ្ឋធានីវិញ។ ពេលនោះហើយដែលគាត់បានទទួលនូវការសិក្សានឹងបទពិសោធន៍ ដែលធ្វើឲ្យគាត់មានលិទ្ធិភាពនឹងក្លាយទៅជាសកម្មជនទាល់សព្វថ្ងៃនេះ។

ក្នុងឋានះជានាយកនៃ (CLEC) វីរះ ជាអ្នកមើលការខុសត្រូវសកម្មភាពរបស់អង្គការនេះជាមួយគ្នានឹងកម្មវិធីផ្សេងទៀតដ៏ច្រើន ដែលគាំទ្រការសិក្សាខាងច្បាប់ខាងការប្រគល់អំណាចនឹងខាងការគាំទ្រក្រុមដែលអាចធ្វើជាអ្នកដឹកនាំសហភាពអ្នកគ្រប់គ្រង នឹងខាងការគាំទ្រការរងគ្រោះដោយសារការអនុវត្តការរិបអូសយកដីរបស់ប្រជាជន។

ការប្តេជ្ញាចិត្តរបស់គាត់ ចំពោះប្រទេសកម្ពុជាបានបញ្ជាក់ឡើងតាមតួនាទីរបស់គាត់ ក្នុងកិច្ចការសង្គម ក្នុងឋានះជាអ្នកដឹកនាំប្រជាជន វិរះបានត្រូវគេទទួលស្គាល់ថាជាអ្នកគាំទ្រសិទ្ធិមនុស្ស។ នៅឆ្នាំ ២០០៥ គាត់ត្រូវគេចាប់ដាក់គុកពីការទំនាក់ទំនងនឹងពាក្យសរសេរលើទង់រិះគន់រដ្ឋាភិបាល។ បើគ្មានការជំទាស់ពីអន្តរជាតិទេ វីរះប្រហែលជាត្រូវជាប់គុកយូរជាងនេះទៅទៀតនៅគុកព្រៃស។ គាត់ជាប់ក្នុងគុកចំនួន ១១ ថ្ងៃ ហើយក្នុងឆ្នាំ ២០០៦ ច្បាប់របស់អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហ-ប្រជាជាតិនៅកម្ពុជា ត្រូវបានសរសេរឡើងវិញដោយបដិសេធមិនឲ្យដាក់គុកបទល្មើសពីការបង្ខូចកេរ្តិ៍ឈ្មោះ។ វីរះសង្ឃឹមថា ការងាររបស់គាត់នឹងជួយបង្កើតជាមូលដ្ឋានរបស់ប្រជាជនខ្មែរជាន់ក្រោយ។ គាត់នឹងខំពង្រឹងសមត្ថភាពប្រជាជនពីព្រោះគាត់មានជំនឿថា ដើម្បីឲ្យប្រជាជនជាន់ក្រោយអាចសំរេចអនាគតខ្លួនឯងបាន គេត្រូវតែរួមចំណែកក្នុងការបញ្ចេញមតិ។



His commitment to Cambodia is also expressed by his role in civil society; as a civilian leader, Virak is known for his human rights advocacy. In 2005, he was jailed for his connection to banners that displayed criticisms of the Cambodian government. If not for the international protest that resulted from his arrest, Virak may have spent much longer in Prey Sar prison. He was released after eleven days, and in 2006, due in part to his advocacy and public pressure, Cambodia's UNTAC law concerning criminal defamation was rewritten to exclude imprisonment as a lawful punishment.  Virak hopes his work helps establish a foundation of active citizenship for young people. He looks to build their capacity as civilians because he believes that for young people to determine the future, they have to be a part of the decisions that shape it.



# ឡុង ខែត

ដើម្បីរំលឹកដល់ការរត់លូនឆ្លងកាត់ខេត្តនាៗ នៅពេលរត់គេចពីការទំលាក់គ្រាប់បែក ដោយសហរដ្ឋអាមេរិក ឪពុកម្តាយគាត់ក៏ដាក់ឈ្មោះឲ្យគាត់ថាខែត។ ខែត នៅក្មេងនៅឡើយមិនអាចចងចាំអ្វីៗទាំងអស់ដែលកើតឡើងក្នុងរបបខ្មែរក្រហមបានទេ ថ្វីត្បិតតែគាត់បានរស់នៅក្នុងសម័យនោះ។ គាត់ចាំយ៉ាងច្បាស់អំពីកុមារភាពនៅពេលក្រោយសង្គ្រាម ពេលដែលកុមារភាគច្រើនជាក្មេងកំព្រា ថាអំពើឃោរឃៅគឺសឹងថាជាអំពើតែមួយគត់ សំរាប់ដោះស្រាយបញ្ហាផ្សេងៗ ហើយម្នាក់ៗមានអារម្មណ៍ដែលអស់សង្ឃឹមយ៉ាងក្រៃលែង។ រហូតដល់ពេលគាត់បានចូលរៀននៅសាកលវិទ្យាល័យ ទើបគាត់ចាប់ផ្តើមយល់ជាងមុន ពីជីវិតរបស់គាត់ដែលមានទំនាក់ទំនងនឹងស្ថានភាពរបស់ប្រទេស៖ "ខ្ញុំនិយាយជាមួយមិត្តឯទៀតៗអំពីប្រវត្តិសាស្ត្រដែលយើងបានរៀនក្នុងថ្នាក់នឹងស្ថានភាពរបស់ប្រទេស នឹងរបៀបណាដែលយើងក្នុងលក្ខណៈជាអ្នកចេះដឹងអាចជួយបាន....យើងខំធ្វើឲ្យកើតសេចក្តីសង្ឃឹមសំរាប់ខ្លួនយើង( មុននេះគឺគ្មានការសង្ឃឹមនេះទេ)"។

ខែតជាមនុស្សម្នាក់ក្នុងចំណោមអ្នកទាំងបួន ដែលជាស្ថាបនិកនៃក្រុមការងារយុវសន្តិភាព ដែលជាអង្គការក្រៅរដ្ឋាភិបាលកើតឡើងនៅឆ្នាំ២០០១ សំរាប់ជួយនិស្សិតខ្មែរឲ្យមានការរីកចំរើនពីជំនាញខាងការរិះគន់។ គាត់ពន្យល់ថា មនុស្សភាគច្រើនដែលនៅរស់ពីសង្គ្រាមបានចែកបទពិសោធន៍នេះទៅកូនរបស់គេ។ គាត់ធ្វើសំណើរថាឥរិយាបថ ដូចជាការជៀសវាង ការប្រុងប្រយ័ត្ន ការធ្វើតាមមេដឹកនាំនឹងការមិនគិតដល់បំណងទៅថ្ងៃមុខ គឺជាចំណែកនៃអាកប្បកិរិយារបស់មនុស្សដែលពិបាកផ្លាស់ប្តូរដែលគាត់ឃើញនៅតែមានបន្តក្នុងជំនាន់យុវជនជាន់ក្រោយ៖ "អ្នកនៅរស់បង្រៀនកូនឲ្យចេះរស់នៅក្នុងសង្គមដែលបំបិតសេរីភាព... ធ្វើពើដូចមិនឮ

# Long Khet

In memory of running across provinces to escape American carpet bombs, his parents named him Khet. Khet was too young to remember the KR times, but he grew up in its echoes. He recalled clearly his childhood in post-war Cambodia, where many children were orphans, violence was merely a way to get things done, and there was an immense sense of hopelessness. It was not until he studied at university that he began to better understand his life in connection to the country's situation: *"I talked with friends about the history we learned in class and the country's situation…and how we who have an education can help…We were creating hope for ourselves [where before there wasn't any]."*

Khet is one of four founders of Youth For Peace (YFP), a non-governmental organization established in 2001 to help Khmer students develop critical thinking skills. He explained that many individuals who survived Cambodia's time of war passed the survival skills they learned to their children. He suggested behaviors like avoiding attention, following the leader, and not making long-term goals are part of the survival mindset that he sees continuing in the young generation: *"They [survivors] teach their children how to survive in a repressive society…pretending to not hear or see anything, that's part of the way they think, and it's what they pass on. That's why we have to work with young people to give them some sort of option, some way of critical thinking and self-expression to create a culture of democracy."*

For the past ten years, he has helped provide a safe space for youth to not only identify and discuss issues in society, but also recognize



ឬមិនឃើញអ្វីសោះ នេះជាចំណែកនៃគំនិតរបស់គេ ហើយគឺគំនិតនេះហើយដែលគេបង្រៀនបន្ត។ ដូច្នេះហើយ យើងត្រូវតែសហគមជាមួយប្រជាជនជាន់ក្រោយ ដើម្បីផ្តល់ឲ្យគេនូវអ្វីៗដែលជាគំនិតរិះគន់នឹងជាការបង្ហាញទស្សនះរបស់បុគ្គលម្នាក់ៗ ដើម្បីបង្កើតវប្បធម៌លទ្ធិប្រជាធិតេយ្យ "។

ក្នុងរយៈពេលដប់ឆ្នាំនេះ គាត់បានជួយផ្តល់កន្លែងដែលមានសុវត្ថិភាពដល់យុវជនដោយមិនគ្រាន់តែខំរកមើលនឹងពិភាក្សាបញ្ហាក្នុងសង្គមប៉ុណ្ណោះទ ប៉ុន្តែថែមទាំងទទួលស្គាល់ការទទួលខុសត្រូវរៀងៗខ្លួន ដើម្បីជាចំណែកនៃដំណោះស្រាយ។ យុវជនមេដឹកនាំដើម្បីសន្តិភាព ជាកម្មវិធីមួយក្រោមការដឹកនាំរបស់យុវសន្តិភាពបង្រៀនសហគមន៍ពីការប៉ាន់ប្រមាណសេចក្តីត្រូវការ នឹងការសម្របសម្រួលថវិការនៃមជ្ឈដ្ឋានរបស់និស្សិត បណ្ណាល័យនឹងបុគ្គលិក ដើម្បីចាត់ចែងធ្វើការបង្ហាត់នៅភ្នំពេញ នៅជុំវិញ០សហគមន៍នឹងខេត្តនាៗ។

their responsibility to be a part of the solution. Young Leaders for Peace, one of several programs under YFP's direction, teaches community needs assessment and budget planning to prepare students for community development work. Apart from its courses, YFP accommodates a student center, a library, and a supportive staff to operate workshops in Phnom Penh, surrounding communities, and other provinces.



CPCS

Centre for Peace and Conflict Studies

The Centre for Peace and Conflict Studies is home to a range of interconnected programmes that promote the advancement of peace processes, research and learning. It creates opportunities for practitioners, students, academics and analysts to access information and resources that are contextually grounded.

www.centrepeaceconflictstudies.org